ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 010 67 67 67 / 010 67 2222
ឆ្នាំទី 7 លេខទី 161 ថ្ងៃទី 1-30 មេសា ឆ្នាំ 2013
ISSUE No 161 5500R

# ទស្សនាវដ្តី ទីក្រុង ព័ត៌មានវិទ្យា

IT MAGAZINE

we live with technology

IT CITY MAGAZINE



- បញ្ឈប់ការរំខាននៃការផ្ញើរ **Email** របស់ Facebook និង Google+
- ចែក **Partition** ជាមួយ Easeus Prartition Master Server
- វិធីសាស្ត្របង្កើត **Recovery Drive**

រចនា
**មនុស្សមុខសំបកឈើ ជាមួយ Ps**

របៀបរចនា
**Image Slideshow**
ដោយប្រើ HTML និងJquiry



CALL CENTER
023 72 72 72
081 72 72 72

Phnom Penh Head Office
60 Monivong Boulevard, Phnom Penh, Cambodia
Siem Reap Office
#8-9, Mondul 2 Village, Svay Dangkum Commune, Siem Reap
Sihanouk Ville Office
Group 1, Village 4, Sangkat 4, Mittapheap, Sihanouk Ville

ONLINE
IN TOUCH WITH YOUR WORLD




ពានរង្វាន់ផ្លាទីនឹម សម្រាប់បច្ចេកវិទ្យាដែលមានគុណភាព
និងពាណិជ្ជនាមល្អផ្តាច់គេ ពីទីក្រុងប៊ែកឡាំង អាល្លឺម៉ង់

# ពានរង្វាន់ ឆ្នាំ ២០១៣

facebook.com/onlineisp

More info.
T: 023/081 72 72 72
E: sales@online.com.kh
W:www.online.com.kh

ONLINE
IN TOUCH WITH YOUR WORLD




Digi

ផ្នែកលក់ ( sms/call ):

**098 888 992 | 098 800 913 | 098 800 617**

ការិយាល័យ: 077/023 22 77 66 | care@digi.com.kh | www.digi.com.kh | f: Digiclub



មានទទួលដោះកូដ
iPhone 4S, 4 ក្នុងតម្លៃ 10$
iPhone 5 តម្លៃ 20$ ប៉ុណ្ណោះ
មកដល់ថ្មី
“On May 19 remind me it's dad's birthday”
Here's your reminder for May 19, 2012 at 9 am:
19 Saturday May 2012
Dad's birthday
Cancel
Confirm
Crop Photo
iPhone 5, 4S, 4, 3GS, 3G និង iPod ដែលនាំចូលពីសហរដ្ឋអាមេរិកទាំងថ្មី
និងមួយទឹកក្នុង តម្លៃទាបជាងទីផ្សារ មានលក់នៅឌីស៊ីខូលិកសិន
DC COLLECTIONS
អាគារលេខ ២២៩-២៣១ ផ្លូវ ១២៨ (កម្ពុជាក្រោម) សង្កាត់មិត្តភាព
ខណ្ឌ៧មករា រាជធានីភ្នំពេញ (ជាន់ក្រោមសណ្ឋាគារប៉ារីស)
ទូរស័ព្ទ : 016 555 889


MAGAZINE
ទស្សនាវដ្ដី
ទីក្រុងទូរស័ព្ទ
ចេញផ្សាយរៀងរាល់ថ្ងៃទី ០១
នៃខែនីមួយៗ...
ផ្ដល់ជូនៈ
▪ ម៉ូដែលទូរស័ព្ទថ្មីៗ និងរបៀបប្រើប្រាស់ទូរស័ព្ទ
▪ តារាងតម្លៃទូរស័ព្ទ
▪ អត្ថបទកម្សាន្តយ៉ាងសម្បូរបែប
▪ ចែកផ្សាយយ៉ាងទូលាយទូទាំង ២៤ រាជធានី_ខេត្ត
រៀងរាល់ថ្ងៃទី ០១ នៃខែនីមួយៗ

USC TECHNOLOGY
THE Technology Solution

GIGABYTE™

Special Promotion

ទិញកុំព្យូទ័រថែម

Flash

Unlimited Versatility Realized
GIGABYTE notebook



Intel® Celeron™ Processor
Intel® HD Graphics 3000
14" 1366x768 LED backlight
2GB DDRIII, 2 slots(Max 4GB)
320GB 2.5" 9.5mm SATA HDD 5400rpm
12.7mm Super Multi DVD RW
Battery Li-ion 6-cell

**$355 + Free Flash 8GB**



2.5" Portable Hard Drive
Pure Classic (USB 2.0)
**$57**

2.5" Portable Hard Drive
A2 (USB 3.0)
**$63**

## Notebook Q2432M



Intel® Core™ i3 2350M (2.3GHz)
14" 1366x768 LED backlight
2GB DDRIII, 2 slots(Max 8GB)
Intel® HD Graphics 3000
750GB 2.5" 9.5mm SATA HDD 5400rpm
12.7mm Super Multi DVD RW
Battery Li-ion 6-cell

**$455**

## Notebook Q2432A



Intel® Core™ i3 2350A (2.3GHz)
14" 1366x768 LED backlight
4GB DDRIII, 2 slots(Max 8GB)
AMD Radeon™ HD6730M 1GB
750GB 2.5" 9.5mm SATA HDD 5400rpm
12.7mm Super Multi DVD RW
Battery Li-ion 6-cell

**$540**

## Notebook Q2440M



3rd Generation Intel® Core™ i3-3120M
Intel® HD Graphics 4000
14" 1366x768 LED backlight
4GB DDRIII, 2 slots(Max 8GB)
750GB 2.5" 9.5mm SATA HDD 5400rpm
9.5mm Super Multi DVD RW
Battery Li-ion 6-cell

**$570**



AMD Dual-Core E450 (1.65GHz)
AMD Radeon™ HD 6320
17.3" Full HD 1920x1080 LED backlight
2GB DDRIII, 2slots ( Max 4GB )
500GB 2.5" 9.5mm SATA HDD 5400rpm
12.7mm Super Multi DVD RW
Battery Li-ion 6-cell, 4400mAh

**$520**

## Notebook P2542G



3rd Generation Intel® Core™ i7-3630QM
15.6" Full HD 1920x1080 LED backlight
8GB DDRIII 1600, 2 slots (Max 16GB)
NVIDIA® GeForce® GTX 660M GDDR5 2GB
128GB mSATA Solid State Drive (m-SSD)
750GB 2.5" 9.5mm SATA HDD 5400rpm
Battery Li-polymer 6-Cell, 4000mAh

**$1399**

## AIO AC21BT



Intel® Pentium® Processor
Intel Media 3151
21.5" 1920X1080 Full HD LED backlight
10-points touchscreen
4GB DDRIII
500GB 2.5" 9.5mm SATA HDD 5400rpm
12.7mm Super Multi DVD RW

**$659**

## Notebook U2442N



Intel® Core™ i5-3210M (2.5GHz-3.1GHz)
14" HD+ 1600x900 LED backlight
8GB DDRIII SO-DIMM
NVIDIA® GeForce® GT 640M 2GB
128GB mSATA Solid State Drive (m-SSD)
750GB 2.5" 9.5mm SATA HDD 5400rpm
Battery Li-polymer 6-Cell, 4000mAh

**$1099**

USC Technology Co, LTD.
Exclusive Authorized Distributor

Address: #79, St.126, S/K. Phsar Thmei 1(North of Central Market), Khan Daun Penh, PP, Cambodia.
Office Tel: (855) 23 223 972. Office Fax: (855) 23 224 861. E-mail: sales@usctechnology.com
Website: www.usctechnology.com


ក្រុមហ៊ុនរ៉ូយ៉ាល់ខេមបូឌា
ROYAL CAMBODIA CO., LTD
Canon
Authorised Distributor
FREE
សួស្តីឆ្នាំថ្មី
បុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ
ផុតកំណត់ត្រឹម
30/04/2013
ជាវម៉ាស៊ីនថតចំលងពណ៌ធម្មជាតិ១គ្រឿងថែមជូនម៉ាស៊ីនទូរសារ១គ្រឿង ម៉ាស៊ីនគិតលេខ WS1610T ១គ្រឿង និងក្រដាស៥ដុំ។
FREE
FREE
ជាវម៉ាស៊ីនថតចំលងស/ខ្មៅ ១គ្រឿងថែមជូនទឹកថ្នាំបន្ថែម ១ប្រអប់ និងក្រដាស៥ដុំ។
ជាវម៉ាស៊ីនទូរសារ ឬ ម៉ាស៊ីនព្រីនធ័រមានមុខងារច្រើន១គ្រឿង ថែមជូនម៉ាស៊ីនគិតលេខ WS1610T ១គ្រឿងនិងក្រដាស៣ដុំ។
No.437, Monivong Blvd, Phnom Penh, Cambodia Tel: 023 428 955 / 012 819 291/ 012 205 111
E-mail: rcccanon@royalgroup.com.kh/ rcccanon_marketing@royalgroup.com.kh
Like us on Facebook
Business Can be simple


PBC បណ្ណាគារ សន្តិភាព
和平書局
PEACE BOOK CENTER
សួស្តីឆ្នាំថ្មី
Selling Stationeries, Books, Sport Equipment, Souvenirs, Making Stamps, Delivery is available.
ORIGINAL TRODAT PRINTY
B1: #435, Preah Monivong Blvd, PP
B2: Opposite National Assembly, PP
B3: #759-761, Monivong, Boeung Trabek, PP
B4: #2, St.271 ⊥ 2002, PP
B5: National Road No.5, Next to UBB, Battambang Province
Tel: 023 222 299 Fax: 023 222 168
华语: 078 618 883 / 077 900 911
Email: info@pbc.com.kh Website: www.pbc.com.kh

# មាតិកា

IT CITY MAGAZINE 161


## ព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ

11- Hennessy V.S.O.P ប្រភេទថ្មីឈានចូលទីផ្សារនៅកម្ពុជា

14- ពិធីតាំងបង្ហាញ Wi-fi SD Card ចូលដល់ទីផ្សារកម្ពុជាហើយ

18- លេចធ្លាយលក្ខណៈពិសេសនៃទូរស័ព្ទ Google Nexus 5

20- Nexus 7 Tablet ជំនាន់ក្រោយរបស់ Asus នឹងចូលរួមនៅ Google 1/0 នៅខែឧសភា

## QUICK STUDY

33- វិធីសាស្រ្តងាយៗនៃការងាររដ្ឋបាល ដោយប្រើ  Mail Merge ក្នុង Word 2013

37- គន្លឹះងាយៗសម្រាប់កែប្រែម៉ោងនៃ Windows 8 Lock Screen

38- បញ្ឈប់ការរំខាន នៃការផ្ញើ Email  របស់ Facebook និង Google+ ទៅកាន់ Email Account

39- វិធីសាស្រ្តបង្កើត Recovery Drive

## GRAPHIC DESIGN & MULTIMEDIA

23- រចនាមនុស្សមុខសំបកឈើ Adobe Photoshop CS5

## SOFTWARE REVIEW

41- ប៊ិនប្រសប់ក្នុងការចែក Partition ជាមួយ Easeus Partition Master Server









**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៊ឹល ច័ន្ទវីរៈ

**នាយកគ្រប់គ្រង**
Mr. : JACKY SAM

**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
លោក : អ៊ុក គំនិត

**ផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ផាន់ ណូរ៉ា
លោក : វង្ស វិច្ឆ័យ
លោក : នួន គីមហុង
លោក : ស្រ៊ុន សេងហុង

**ផ្នែករចនាទំព័រ**
ប្រធានលោក : ស្វាយ សេរីវុត្ថា
កញ្ញា : សរ និមល

**ផ្នែកទីផ្សារ**
លោក : ដួង ចាន់សុភ័ក្រ្ត
លោក : សួន រ៉ា

**ផ្នែកលក់**
ប្រធានលោក : ឈឹម ធុល
លោក : សំរិទ្ធិ រស់ភក្រ្តា



No 8AEo, St. 156, Sangkat Veal Vong,
Khan 7 Makara, Phnom Penh.
Any problem pleas contact us :
023 99 78 99 / 010 67 67 67
www.itcity.com.kh




ចេញលក់ថ្មីនេះហើយ


Microsoft Office 2010
សិក្សាកម្មវិធី
Microsoft Word 2010
ការងាររដ្ឋបាល
Microsoft Excel 2010
ការងារគណនេយ្យ

# មាតិកា

IT CITY MAGAZINE 161


WEB

49- របៀបរចនា Image Slideshow ដោយប្រើ HTML និង Jquiry

ADD ON

56- កម្មវិធីបន្ថែម

NEW FEATURE

58- តើមានអ្វីប្លែកសម្រាប់ Microsoft Office 2013

TOOL TIP

61 - របៀបប្រើប្រាស់ Compression Files ឬ Folder ក្នុង Windows

64- របៀបបង្កើតឲ្យកុំព្យូទ័រ Shut Down ដោយស្វ័យប្រវត្តិនៅពេលលោកអ្នកមិនប្រើប្រាស់

65- របៀបបង្កើតប៊ូតុង Shutdown / Restart / Lock Icons ក្នុង Windows ដោយខ្លួនឯង

67- របៀបបិទ Power Management ក្នុង Windows 7

កម្មវិធីថ្មីៗ

68- ទាញយកកម្មវិធីថ្មីៗ

សំណួរមិត្តអ្នកអាន

72 - សំណួរ និងចម្លើយ

សំណើចមិត្តអ្នកអាន

75- សំណើចមិត្តអ្នកអាន និងរូបភាពអាថ៌កំបាំង

តារាងតម្លៃ

79- តារាងតម្លៃកុំព្យូទ័រ និងគ្រឿងបន្លាស់

ផលិតផលថ្មីៗ

87- ផលិតផលថ្មីៗ



**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៉ុល ច័ន្ទវីរៈ

**នាយកគ្រប់គ្រង**
Mr. : JACKY SAM

**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
លោក : អ៊ុក គំនិត

**ផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ផាន់ ណូរ៉ា
លោក : វង្ស វិច្ឆ័យ
លោក : នួន គីមហុង
លោក : ស្រ៊ុន សេងហុង

**ផ្នែករចនាទំព័រ**
ប្រធានលោក : ស្វាយ សេរីវុត្ថា
កញ្ញា : សរ និមល

**ផ្នែកទីផ្សារ**
លោក : ដួង ចាន់សុភ័ក្ត្រ
លោក : សួន រ៉ា

**ផ្នែកលក់**
ប្រធានលោក : ឈឹម ធុល
លោក : សំរិទ្ធិ រស់ភក្ត្រា



No 8AEo, St. 156, Sangkat Veal Vong,
Khan 7 Makara, Phnom Penh.
Any problem pleas contact us :
023 99 78 99 / 010 67 67 67
www.itcity.com.kh








# Hennessy V.S.O.P ប្រភេទថ្មីឈានចូលទីផ្សារនៅកម្ពុជា



នៅក្លឹប True Face ក្រុមហ៊ុនស្រា Hennessy បានរៀបចំសន្និសីទសារព័ត៌មានដើម្បីប្រកាសសម្ពោធស្រា Hennessy V.S.O.P ថ្មីដែលមានឈ្មោះថា Hennessy V.S.O.P. Privilege Collection KYRIOS កាលពីរសៀលថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣ កន្លងទៅនេះ។

នៅក្នុងពិធីសម្ពោធនោះដែរក៏មានការអញ្ជើញចូលរួមពីកំពូលតារាចម្រៀងល្បីឈ្មោះកញ្ញាឱក សុគន្ធកញ្ញានិងក្រុមអ្នកសារព័ត៌មានជាតិនិងអន្តរជាតិជាច្រើននាក់ចូលរួមក្រេបរស់ជាតិដ៏ស្រទន់របស់ក្រុមហ៊ុនស្រា Hennessy ដែលមានរសជាតិស្រា Hennessy V.S.O.P Privilege Collection KYRIOS ដែលជាផលិតផលថ្មីសម្រាប់ប្រទេសកម្ពុជា។

អ្នកតំណាងក្រុមហ៊ុនស្រា Hennessy ក៏បានបង្ហាញពីលក្ខណៈពិសេស និងរសជាតិរបស់ Hennessy V.S.O.P. Privilege Collection KYRIOS ដោយអះអាងថាស្រា Hennessy ប្រភេទថ្មីនេះមានសញ្ញាសម្គាល់នៃភាពល្បីល្បាញរបស់ខ្លួនដែលមាន៥ចំនុចមានដូចជា «ផ្លែទំពាំងបាយជូរ» «ដៃកាន់អាវុធ» «ឆ្នាំ១៨១៧» «ពណ៌ទង់ដែង» និង «ស្រមោលថ្មី» ដែលសុទ្ធតែជាមិនិត្តរូបនៃស្រា Hennessy V.S.O.P. Privilege Collection KYRIOS ។

នៅយប់ថ្ងៃដដែលក្នុងឱកាសបង្ហាញស្រា Hennessy V.S.O.P. Privilege Collection KYRIOS នេះក៏មានការប្រគុំតន្ត្រីដែលអញ្ជើញចូលរួមដោយតារាចម្រៀងកញ្ញា ឱក សុគន្ធកញ្ញា ព្រមទាំងតារាជាច្រើនរូបផ្សេងទៀតផងដែរ។ អ្នកតំណាងរូបនេះបានបន្ថែមទៀតថាក្នុងនាមក្រុមហ៊ុនទាំងមូលលោកសូមថ្លែងអំណរគុណទៅដល់អតិថិជនដែលតែងតែគាំទ្រ Hennessy កន្លងមកហើយលោកក៏បានសំណូមពរទៅដល់អតិជនឱ្យគាំទ្របន្ថែមទៀតក្រុមហ៊ុននឹងបន្តនាំមកជូនអតិថិជននូវអ្វីគ្រប់បែបយ៉ាងដែលអតិថិជនចង់បានតាមតម្រូវការ។

ក្នុងឱកាសដ៏សប្បាយរីករាយនោះកញ្ញាឱក សុគន្ធកញ្ញា ក៏បានមានប្រសាសន៍ថា “នាងខ្ញុំមានសេចក្តីសប្បាយរីករាយខ្លាំងមែនទែន ព្រោះថា រាល់កម្មវិធីរបស់ Hennessy គឺតែងតែមានវត្តមាននាងខ្ញុំចូលរួមជានិច្ច។ ក្នុងឱកាសប្រគំតន្ត្រីនេះ នាងខ្ញុំក៏បានជ្រើសរើសយកបទចម្រៀងថ្មីៗជាពិសេសបបទញាក់កន្ត្រាក់អារម្មណ៍ដើម្បីកំដរទៅដល់ទស្សនិកជនផងដែរ“។ គួរបញ្ជាក់ថា ស្រា Hennessy នឹងធ្វើការប្រគំតន្ត្រីនៅតាមបណ្តាក្លឹបកម្សាន្តនានានៅក្នុងរាជធានីចំនួនបួនកន្លែងដែលប្រព្រឹត្តនៅថ្ងៃទី ១៥ ,២២, ២៣ និង ២៥ ខែមីនា ឆ្នាំ២០១៣ នេះ ដោយមានការចូលរួមពីកំពូលតារាចម្រៀង ឱក សុគន្ធកញ្ញា និងតារាល្បីជាច្រើនរូបមកពីប្រទេសកម្ពុជា និងនៅជុំវិញពិភពលោក៕ (អត្ថបទក្រុមហ៊ុន)


SALE
ផ្ទះលក់ និងជួល
- ផ្ទះស្ថិតក្នុងទីក្រុងរណប ប្រកបដោយ
ផាសុខភាព និងមានសុវត្ថិភាពគ្រប់គ្រាន់ ។
- ខ្យល់អាកាសបរិសុទ្ធ ។
- មានទឹក ភ្លើង និងកន្លែងចតរថយន្ត
ធំទូលាយ ។
ទីតាំងស្ថិតនៅ :
Grand Phnom Penh
International City
ទំនាក់ទំនង :
016 58 58 99
010 67 67 67


Thmey Thmey
គេហទំព័រព័ត៌មានថ្មីៗ
លោកអ្នកអាចស្វែងរកព័ត៌មានថ្មីៗ ព័ត៌មានវីដេអូ បទវិភាគ
បទសំភាសន៍ នយោបាយ និងព្រឹត្តិការណ៍ជាតិ និងអន្តរជាតិ
ជាច្រើនទៀត ជាមួយគេហទំព័រថ្មីៗ
សើវីងវិប
Serving Web
Developed by
Serving Web Solution
Online News
គេហទំព័រថ្មីៗនាំជូនលោកអ្នកនូវ
ព័ត៌មានតាមអ៊ិនធើណេត | Online News
ការផ្សព្វផ្សាយពាណិជ្ជកម្ម | Advertising
ការណែនាំផលិតផលថ្មីៗ និង | Product Review and
ការថតស្ពតវីដេអូ | Video Spot Recording
គេហទំព័រព័ត៌មានសម្បូរបែប
ទំនាក់ទំនង : Nº. 3AE0, Street. 230, Phsar Deum Kor, Toul Kork, Phnom Penh Cambodia
Advertising : H/P: (855) 16 485 627 / 16 500 521 / 12 986 101
General Inquiry : H/P: (855) 23 885 690
E-mail : info@thmeythmey.com / sales@thmeythmey.com
www.thmeythmey.com
Multi Media Online News
& Products Review



# ក្រុមហ៊ុន FORD MOTOR បានប្រារព្ធកម្មវិធី តាំងពិព័រណ៍រថយន្តខ្នាតអន្តរជាតិ ដែលពុំធ្លាប់មាននៅកម្ពុជា

នៅសាលមហោស្រពកោះពេជ្រ ក្រុមហ៊ុន Ford Motor បានធ្វើការដាក់បង្ហាញនូវរថយន្តលំដាប់ថ្នាក់ពិភពលោកដែលមានបំពាក់ទៅដោយបច្ចេកវិទ្យាទំនើប និងជាប្រភេទរថយន្តដែលផលិតឡើងក្រោមយុទ្ធសាស្ត្រ Ford តែមួយសម្រាប់ទីផ្សារកម្ពុជាដែលបានប្រារព្ធកម្មវិធីបើកសម្ពោធ ពិធីតាំងពិព័រណ៍រថយន្តខ្នាតអន្តរជាតិក្នុងរាជធានីភ្នំពេញនាព្រឹកថ្ងៃទី១៥ ១៦ ១៧ ខែមីនា ឆ្នាំ ២០១៣ កន្លងទៅនេះ។

លោក D.J. Simpson នាយកគ្រប់គ្រងផ្នែកពង្រីកប្រតិបត្តិការ និងការនាំចេញប្រចាំតំបន់អាស៊ីអាគ្នេយ៍ បានមានប្រសាសន៍ថា វត្តមានរបស់ Ford នៅក្នុងកម្មវិធីតាំងពិព័រណ៍រថយន្តនេះបានបង្ហាញពីប្រភេទរថយន្តដ៏ច្រើនបំផុតពុំធ្លាប់មានរបស់ Ford ដែលមាននៅកម្ពុជា និងជាការឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់ក្រុមហ៊ុនក្នុងការផ្តល់ជូននូវប្រភេទរថយន្តដែលអតិថិជនចង់បាន និងផ្តល់តម្លៃ។

លោកបានមានប្រសាសន៍បន្ថែមទៀតថា យើងបានព្យាយាមអភិវឌ្ឍនូវរថយន្តប្រភេទ Sedan រថយន្ត Ford Taurus សេរីឆ្នាំ២០១៣នេះ ដោយការយកចិត្តទុកដាក់និងផ្ចិតផ្ចង់បំផុត ហើយយើងសង្ឃឹមថា រថយន្តនេះនឹងទទួលបានការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់អតិថិជននៅកម្ពុជា។ ក្រុមហ៊ុន RMA Cambodia បានទទួលនូវកិត្តិយសយ៉ាងល្បីរន្ទឺ ក្នុងនាមជាក្រុមហ៊ុនដែលទទួលបាន នូវ សិទ្ធិ ចែកចាយ រថយន្ត Ford ផ្តាច់មុខពីក្រុមហ៊ុន Ford Motor ចាប់តាំងពី ឆ្នាំ១៩៩។ ក្រុមហ៊ុន RMA Cambodia បាននាំយករថយន្តFord មកទីផ្សារកម្ពុជា និងធ្វើការភ្ជាប់ទំនាក់ទំនងរវាងក្រុមហ៊ុន និងអតិថិជន។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាបន្ទាន់របស់អតិថិជន មជ្ឈមណ្ឌលជួសជុលនិងថែទាំរថយន្ត Ford របស់ក្រុមហ៊ុន RMA Cambodia ទាំងនៅក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប បានបំពាក់ទៅដោយបច្ចេកវិទ្យាដ៏ទំនើបៗនិងសម្ភារបែបជាច្រើន រួមជាមួយជាងជំនាញដែលទទួលបានការបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវសម្រាប់ធានាដល់ការផ្តល់ជូននូវសេវាដ៏ល្អឥតខ្ចោះនៅគ្រប់ទីកន្លែង។

ឯកឧត្តម ចម ប្រសិទ្ធិ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថានៅឆ្នាំ ២០១៨ តំបន់អាស៊ាននឹងក្លាយជាកន្លែងផលិតរថយន្តដ៏ធំជាងគេ នៅលើពិភពលោកចំណាត់ទី ៦ ដូច្នេះរយៈពេលប៉ុន្មានឆ្នាំទៀតអាស៊ាននិងចូលចំណាត់ថ្នាក់ទី ៦ នៅក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ ក្នុងចំណោមប្រទេសផលិតរថយន្តនៅអាស៊ាន។ ឯកឧត្តម ក៏មានប្រសាសន៍បន្តទៀតថា ការតាំងពិព័រណ៍ជាលើកដំបូងខ្នាតអន្តរជាតិនេះគឺការតាំងពិព័រណ៍យានយន្តនៅក្នុងទីក្រុងភ្នំពេញ ហើយនឹងបន្តជារៀងរាល់ឆ្នាំ ការតាំងពិព័រណ៍នេះក៏នៅក្នុងកម្មវិធីតាំងពិព័រណ៍ផ្សេងៗទៀតនៅក្រសួងពាណិជ្ជកម្ម ដើម្បីទាក់ទាញឲ្យក្រុមហ៊ុនជាច្រើនទៀតចូលរួមឲ្យបានកាន់តែច្រើន ក្នុង សក្តានុពល នៅក្នុង ប្រទេសកម្ពុជា យើង។ ការតាំងពិព័រណ៍រយៈពេលបីថ្ងៃគឺថ្ងៃទី១៥ ១៦ ១៧ ខែមីនា ឆ្នាំ២០១៣នេះ នាំនូវភាពជោគជ័យដល់អ្នកតាំងពិព័រណ៍ក៏ដូចជាការនាំមកនូវអារម្មណ៍ប្លែកៗដល់អ្នកទស្សនាទាំងនោះផងដែរ។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះប្រធាននៃសហព័ន្ធយានយន្តកម្ពុជា លោក វ៉ាមី វ៉ាហ្វ៊ែរ ដែលបានរៀបចំនូវការតាំងពិព័រណ៍ខ្នាតអន្តរជាតិនៅរាជធានីភ្នំពេញអំពីយានយន្តឆ្នាំ ២០១៣ ជាលើកទីមួយ ដែលជាព្រិត្តិការណ៍មួយបង្កើតឲ្យមានការយល់ដឹងបន្ថែមទៀតពីសក្តានុពលនិងអង្គការដើម្បីវិនិយោគនៅក្នុងវិស័យឧស្សាហកម្មយានយន្តដែលកំពុងរីកចម្រើននៅក្នុងប្រទេសកម្ពុជា៕













# ពិធីតាំងបង្ហាញ Wi-Fi SD Card ចូលដល់ទីផ្សារកម្ពុជាហើយ












កាល ពីល្ងាច ថ្ងៃ ទី ០៧ ខែ មិនា ឆ្នាំ ២០១៣ ក្រុមហ៊ុន Smart Computer បានរៀបចំកម្មវិធីបង្ហាញផលិតផលថ្មីរបស់ខ្លួននៅសណ្ឋាគារភ្នំពេញ។ កម្មវិធីនោះ បាន ធ្វើបទបង្ហាញ ពីផលិតផល ថ្មីរបស់ក្រុមហ៊ុន Transcend ដែលជាក្រុមហ៊ុនលំដាប់ពិភពលោក។ នៅក្នុងកម្មវិធីនោះដែរយើងឃើញមានការចូលរួមពីសំណាក់ដៃគូចែកចាយរបស់ក្រុមហ៊ុន Smart Computer ជាច្រើនដែលភាគច្រើនជាហាងលក់កុំព្យូទ័រ និងគ្រឿងបច្ចេកវិទ្យានៅក្នុងរាជធានីភ្នំពេញ។

លោក POR ជានាយកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុន Transcend ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថានៅក្នុងការផលិតនូវផលិតផលបច្ចេកវិទ្យាថ្មីសម្រាប់ឆ្នាំ ២០១៣ នេះគឺ ក្រុមហ៊ុន Transcend បានបង្កើត Wi-Fi SD Card ដែលជាប្រភេទអង្គចងចាំដែលមានគុណភាព និងសមត្ថភាពខ្ពស់បំផុត ហើយលក្ខណៈពិសេសរបស់វាគឺអាចភ្ជាប់ជាមួយឧបករណ៍បាន៣ ជាមួយសមត្ថភាព Wireless របស់វាព្រមទាំងអ្នកអាចប្រើប្រាស់ Tablet / Smart Phone / Notebook ដើម្បីមើលរូបភាពទាំងនោះនៅក្នុងពេលតែមួយ និង លោកអ្នកអាច Upload រូបភាពដោយផ្ទាល់ទៅកាន់បណ្តាញសង្គម យ៉ាង ងាយ ស្រួល បំផុត។ មិនត្រឹមតែប៉ុណ្ណោះវាអាចស្គាល់ជាមួយប្រព័ន្ធប្រតិបត្តិការដូចជា iOS, Android, Windows, Linux និង Mac OS X ទៀតផង។ លោកបានបន្តទៀតថា ការតាំងបង្ហា ញនេះដែរមានផលិតផលជាច្រើនទៀតដូចជា Wireless Products & DVD Writers, Solid State Drives, External Hard Drives, USB Flash Drives, Memory Cards, Card Readers &Accessories, Digital Music Players, Digital Photo Frames, and Memory Modules.ហើយមានលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលឆាប់ៗនេះ។ លោកក៏បានអរគុណដល់អតិថិជនទាំងអស់ដែលបានជួយគាំទ្រដល់ផលិតផលរបស់ Transcend ជារៀងរហូតមកដែលធ្វើឲ្យផលិផល Transcend មានទីផ្សារនៅព្រះរាជាណាចក្រមានភាពល្បូតលាស់គួរជាទីមោទន។

ដើម្បីឲ្យមានភាពកាន់តែស្និតស្នាលក្រុមហ៊ុន Transcend បានប្រគល់វិញ្ញាបត្រដល់ក្រុមហ៊ុន Smart Computer ផងដែរ។ ព្រមទាំងបានថតរូបទុកជាអនុស្សាវរីយ៍រួមគ្នាជាមួយនឹងម្ចាស់ហាងលក់កុំព្យូទ័រនៅក្នុងរាជធានីភ្នំពេញ និងក៏បានពិសារអាហារពេលល្ងាចយ៉ាងរីករាយជាមួយអតិថិជនអ្នកគាំទ្រ៕

# ក្រុមហ៊ុន LG ផលិត Smartwatch ដែរ !

សព្វថ្ងៃនេះ ក្រុមហ៊ុន LG កំពុងតែដំណើរការផលិតនូវនាឡិកាដ៏ឆ្លាតវៃ Smartwatch សម្រាប់ប្រកួតប្រជែងជាមួយក្រុមហ៊ុនបច្ចេកវិទ្យាធំៗនៅលើពិភពលោកដូចជា Apple , Google, LG និង Samsung ដែលបានផលិតកាលពីខែមុន។

បន្ទាប់ពីមានពាក្យចចាមអារ៉ាមលេចឡើងកាលពីដើមឆ្នាំនេះថា ក្រុមហ៊ុន Apple បានកំពុងតែដំណើរការផលិតនូវ Smartwatch ដ៏អស្ចារ្យរបស់ខ្លួន ទើបមានក្រុមហ៊ុនមួយចំនួនបានយកលំនាំតាមក្រុមហ៊ុន Apple ដើម្បីផលិត Smartwatch ជាកម្មសិទ្ធរបស់ក្រុមហ៊ុនខ្លួនដែរ។ ជាក់ស្តែងដូចជាក្រុមហ៊ុន LG ជាដើម កាលពីមុនជាក្រុមហ៊ុនផលិតស្មាតហ្វូននោះទេ ដោយឃើញថា Apple ផលិត Smartwatch ទើបសព្វថ្ងៃនេះ LG ចាប់ផ្តើមផលិតដែរ។



យោងតាមប្រភពរបាយការណ៍ដែលទើបតែចេញផ្សាយនាពេលថ្មីៗនេះបានឲ្យដឹងថាការផលិតឬការបង្កើតឡើងនៃ Smartwatch ដ៏ឆ្លាតវៃរបស់ក្រុមហ៊ុន LG ក៏ដូចជារបស់ក្រុមហ៊ុន Apple ដែរ សុទ្ធតែជាគម្រូដ៏ល្អមួយដើម្បីសម្រេចបានភាពជោគជ័យដ៏ធំធេង ដូច Google Glasses ដែលមានវត្តមាននៅលើជំនួញទីផ្សារកន្លងមកនេះ។ ដោយឡែក បើយោងតាមប្រភពព័ត៌មានមកពី Korean Time ក៏បានបញ្ជាក់ខ្លះៗផងដែរថា ការផលិតនូវ Smart watch នេះឡើងគឺពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់សម្រាប់ពេលអនាគត៕




ហាងលក់សំលៀកបំពាក់
DC COLLECTIONS
Valentino Rudy
ITALY
KIRKLAND
Signature
pierre cardin
INTERNATIONAL
DAKS
ungaro
PHIL




ហាងលក់សំលៀកបំពាក់
DC COLLECTIONS

អាគារលេខ ២២៩-២៣១ ផ្លូវ ១២៨ (កម្ពុជាក្រោម) សង្កាត់មិត្តភាព
ខណ្ឌ៧មករា រាជធានីភ្នំពេញ (ជាន់ក្រោមសណ្ឋាគារប៉ារីស)
ទូរស័ព្ទ : 016 555 889 / 018 79 79 79 / 069 67 67 67




# លេចធ្លាយលក្ខណៈពិសេសនៃទូរស័ព្ទ Google Nexus 5

ក្រុមហ៊ុន LG កាលពីពេលកន្លងទៅនេះបានផលិតនូវស្មាតហ្វូនម៉ូដែល Nexus 4 សម្រាប់ក្រុមហ៊ុន Google ហើយសព្វថ្ងៃនេះមានពាក្យចចាមអារ៉ាមមួយចំនួនលើកឡើងថាក្រុមហ៊ុន LG កំពុងតែដំណើរការផលិតនូវប្រភេទ Nexus Smartphone មានឈ្មោះថា Google Nexus 5 ឬ LG Nexus 5។

យោងតាមប្រភពព័ត៌មានដែលទើបតែចេញផ្សាយក្នុងពេលថ្មីៗនេះបានបង្ហាញថាទូរស័ព្ទស្មាតហ្វូនម៉ូដែល Google Nexus 5 ជំនាន់ថ្មីនេះត្រូវបានរចនាឡើងដោយមានបំពាក់មកជាមួយអេក្រង់ប្រភេទ OLED Full HD ទំហំ5.2 អ៊ីង ជាមួយ Resolution: 1920 x 1080 ភិចសែល ដើរដោយអង្គប្រតិបត្តិការ Qualcomm Snapdragon 800 Processor មានល្បឿន 2.3GHz អង្គចងចាំ ទំហំ3GB និងទំហំផ្ទុកទិន្នន័យជាប់ម៉ាស៊ីនមានបីជម្រើសសម្រាប់ ជ្រើសរើសគឺ 16GB 32GB និង64GB ។

លក្ខណៈពិសេសបន្ថែមលើសនេះទៅទៀតរួមមានកម្រិតកាមេរ៉ាផ្នែកខាងក្រោយទំហំ16 មេហ្គាភិចសែលជាមួយនឹងសមត្ថភាពពិសេសគឺអាច record 4k សម្រាប់វីដេអូកម្រិត 30 fps និង 1080p កម្រិត 60 frames ក្នុងមួយវិនាទី និងកម្រិតកាមេរ៉ាខាងមុខជា VGA Camera ទំហំ2.1 មេហ្គាភិចសែល។

ដោយឡែកថាមពលថ្មវិញវាអាចផ្ទុកបានរហូតដល់ 3300mAh ហើយគួរបញ្ជាក់ថាលក្ខណៈទាំងអស់នេះគ្រាន់តែជាព័ត៌មានបែកធ្លាយតែប៉ុណ្ណោះ ព័ត៌មានជាផ្លូវការយ៉ាងណានោះយើងនឹងជម្រាបជូបលោកអ្នកនៅពេលក្រោយៗទៀត៕

ប្រភព:geeky gadgets

Wicam
The best connection

WiCAM Corporation, Ltd
INTERNET SERVICE PROVIDER www.wicam.com.kh



#113, Street 271, Sangkat Boeung Salang, Khan Toul Kork , Phnom Penh City
Tel: (+855) 23 22 40 40 / Fax: (+855) 23 22 25 26
E-mail: info@wicam.com.kh, sales@wicam.com.kh



# Nexus 7 Tablet ជំនាន់ក្រោយរបស់ Asus នឹងចូលរួមនៅ Google I/O នៅខែឧសភា

តាមប្រភពព័ត៌មានដែលចេញផ្សាយនាពេលថ្មីៗនេះបានឲ្យដឹងថាក្រុមហ៊ុន Googleនឹងប្រារព្ធពិធីសន្និសីទI/ODeveloperConferenceនៅខែឧសភាខាងមុខនេះ ដោយក្រុមហ៊ុន នឹងធ្វើការផ្សព្វផ្សាយពីប្រព័ន្ធប្រតិបត្តិការជំនាន់ក្រោយគឺAndroid 5.0 Key Lime Pie។

ស្របពេលជាមួយនឹងការប្រកាសពីប្រព័ន្ធប្រតិបត្តិការនេះដែរក្រុមហ៊ុននឹងធ្វើការប្រកាសថា តើឧបករណ៍ណាខ្លះដែលអាចទទួលយកនូវ Android 5.0 Key Lime Pie ជំនាន់ក្រោយនេះហើយនៅពេលនោះយើងសង្ឃឹមទុកជាមុនថានឹងឃើញមានវត្តមាននៃប្រភេទ Nexus 7 tablet របស់ Asus បង្ហាញខ្លួននៅ Google I/O នេះដែរ។

យោងតាមសម្តីរាយការណ៍របស់ក្រុមហ៊ុន Asus បានឲ្យដឹងថាក្រុមហ៊ុនរបស់ខ្លួននឹងធ្វើការបង្ហាញនូវ Nexus 7 Tablet ជំនាន់ក្រោយនៅ Google I/O នៅខែឧសភាដោយដាក់លក់ក្នុងតម្លៃ 249 ដុល្លារហើយអ្វីដែលគេរំពឹងទុកយ៉ាងមុតមាំនោះគឺថាអាចប្រកួតប្រជែងជាមួយ Tablet ទំហំ7 អ៊ីង និង 8 អ៊ីង របស់ក្រុមហ៊ុនដទៃទៀត។

អ្វីដែលពិសេសសម្រាប់ប្រភេទ Google Nexus 7 ជំនាន់ក្រោយនេះគឺនឹងមានបំពាក់មកជាមួយអេក្រង់ដ៏ភ្លឺច្បាស់ប្រភេទ Full HD និងProcessor ដ៏លឿនទៀតផង៕

ទស្សនាវដ្តី ទីក្រុងព័ត៌មានវិទ្យា IT CITY MAGAZINE

ទស្សនាវដ្តី ទីក្រុងទូរស័ព្ទ PHONE CITY MAGAZINE

# សេចក្ដីជូនដំណឹង

ក្រុមហ៊ុនទស្សនាវដ្តី ទីក្រុងព័ត៌មានវិទ្យា ទស្សនាវដ្តី ទីក្រុងទូរស័ព្ទ និងទស្សនាវដ្តី ចន្ទ្រះ មានកិត្តិយសសូមជម្រាបជូនអតិថិជនមិត្តអ្នកអានទាំងអស់ឱ្យបានជ្រាបថា៖ ក្រុមហ៊ុនទស្សនាវដ្តីរបស់យើងខ្ញុំមានផ្ដល់ជូននូវសេវាកម្មជាវទស្សនាវដ្តីប្រចាំឆ្នាំ ដោយខាងក្រុមហ៊ុនយើងខ្ញុំនឹងយកទៅជូនដល់ទីកន្លែងរបស់លោកអ្នកតែម្ដង។

១. ការជាវទស្សនាវដ្តី ទីក្រុងព័ត៌មានវិទ្យា ឬទស្សនាវដ្តី ទីក្រុងទូរស័ព្ទ រយៈពេល ៦ ខែ មានចំនួន ១២លេខ តម្លៃ ៧២,០០០រៀល។
២. ការជាវទស្សនាវដ្តី ទីក្រុងព័ត៌មានវិទ្យា ឬទីក្រុងទូរស័ព្ទ រយៈពេល ១២ ខែ មានចំនួន ២៤លេខ តម្លៃ ១៣៧,០០០រៀល។
៣. ការជាវទស្សនាវដ្តី ចន្ទ្រះ រយៈពេល ៦ ខែ មានចំនួន ៦លេខ តម្លៃ ៣០,០០០រៀល។
៤. ការជាវទស្សនាវដ្តី ចន្ទ្រះ រយៈពេល ១២ ខែ មានចំនួន ១២លេខ តម្លៃ ៦០,០០០រៀល។

អាស្រ័យដូចបានជម្រាបជូនខាងលើ លោកអ្នកអាចទំនាក់ទំនាក់ទំនងជាវ និងសាកសួរព័ត៌មានបន្ថែមតាមរយៈអាសយដ្ឋានផ្ទះលេខ 8AEo ផ្លូវលេខ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខ៖

**010 234 334 / 016 234 334 / 012 999 140**

## ព័ត៌មានអំពីការជាវ

ឈ្មោះ........................ភេទ............អាយុ.............មុខរបរ...................................លេខទូរស័ព្ទ.........................
....

អាសយដ្ឋាន..........................................................................................................................................

ទីតាំងងាយស្វែងរក..........................................................................................អ៊ីមែល...................................

**ជាវទស្សនាវដ្តី** ☐ ទីក្រុងព័ត៌មានវិទ្យា **រយៈពេល** ☐៦ខែ ចាប់ពីលេខទី..................ដល់លេខទី.........................

☐ ទីក្រុងទូរស័ព្ទ ☐១២ខែ ចាប់ពីលេខទី.................ដល់លេខទី.........................

☐ ចន្ទ្រះ

បានពិនិត្យត្រឹមត្រូវ ភ្នំពេញ ថ្ងៃទី.........ខែ.............ឆ្នាំ២០.........

ហត្ថលេខា ហត្ថលេខាអ្នកទទួល

# ក្រុមហ៊ុន Barnes & Noble

## មានផ្តល់ Nook Simple ជាមួយ Nook HD+




ក្រុមហ៊ុន Barnes & Noble ថ្មីៗនេះមាន Services ថ្មីទៀតហើយសម្រាប់ការ លក់ Nook HD+ ដែលជា Tablet e-Reader នៅសហរដ្ឋអាមេរិក ។

កាលពីថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៣ កន្លងទៅនេះក្រុមហ៊ុន Barnes & Noble បានចាប់ផ្តើមដំណើរការលក់ Nook HD+ Tablet និងមានផ្តល់ Nook Simple ដោយមិនគិតថ្លៃ ចាប់ពីថ្ងៃ ២៤ ដល់ ថ្ងៃ ៣០ ខែ មីនា នេះ ។

យោងតាមរបាយការណ៍របស់ក្រុមហ៊ុន Barnes & Noble បាននិយាយថាសម្រាប់ E-Reader នេះគឺមានមុខងារជាច្រើនអាចប្រើប្រាស់បានជាមួយកម្មវិធីផ្សេងៗ ហើយ Tablet នេះគឺជា Multimedia Devices ដែលមាន e-Book ក្នុងការអានកម្សាន្ត ។

បើតាម intomobile បានចេញផ្សាយថា Nook HD+ មានបំពាក់នូវលក្ខណៈដូចជា Full HD 1920x1280 Display Processor Dual-Core ដែលមានល្បឿន 1.5 GHZ ជាមួយ Storage 16GB ឬ 32 GB ព្រមទាំង microSD slot ទៀតផង។

គួរបញ្ជាក់ថា Nook HD+ មានលក់ 16 GB ក្នុងតម្លៃដើម ២៦៩ ដុល្លារ និង 32GB ក្នុងតម្លៃ ២៩៩ដុល្លារ ប៉ុណ្ណោះ៕ ប្រភព: intomobile

ជារឿយៗទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាតែងពាំនាំនូវការរចនា Graphic Design ពីមួយលេខទៅមួយលេខតែងតែមានភាព ខុសគ្នាៗលាយឡំនឹងគំនិតច្នៃប្រឌិតប្លែកៗ វិធីសាស្ត្រល្អៗសម្រាប់ប្រិយមិត្តអនុវត្តន៍តាមដែលទាំងអស់នេះពិតជាមាននៅក្នុងទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាយើង។ ដោយឡែកក្នុងលេខនេះដែរ ក្រុមការងាររបស់យើងនឹងនាំអារម្មណ៍របស់លោកអ្នកមកធ្វើការអនុវត្តន៍ជាមួយនឹងការរចនាដែលមិនធ្លាប់ជួបពីមុនមកនៅក្នុង Adobe Photoshop គឺការរចនាមនុស្សមុខសំបកឈើវិញម្ដង ដែលយើងនឹងធ្វើការបង្ហាញជូនជាជំហានៗដូចខាងក្រោម៖



# រចនា មនុស្សមុខ សំបកឈើ ADOBE PHOTOSHOP CS5

មុននឹងចាប់ផ្ដើមលោកអ្នកត្រូវចូលទៅ Download រូបភាពតាមរយៈគេហទំព័រមួយចំនួន ដែលរូបទាំងនោះមានដូចជា៖

- រូបមុខបុរសម្នាក់ និងរូបសំបកឈើដូចខាងក្រោម



ជាកិច្ចចាប់ផ្ដើមសូមលោកអ្នកបើកកម្មវិធី Adobe Photoshop រួចបង្កើតនូវផ្ទាំងការងារថ្មីមួយដោយចូលទៅកាន់ File > New ឬ Ctrl + N ហើយសូមកំណត់ទំហំ 1563 x 1173 px ព្រមជាមួយនិង Resolution 300 px រួចចុចប៊ូតុង OK ជាការស្រេច ។




## 01

សូមបើករូបបុរសខាងលើចូលទៅក្នុងផ្ទាំងការងាររបស់លោកអ្នក បន្ទាប់មកប្រើ Pen Tool ដោយកំណត់ Paths not Shape Layers ហើយកាត់យកតែមុខតែប៉ុណ្ណោះ(មើលរូប)៖




## 02

សូមធ្វើការចម្លងរូបភាពដោយយកតែពណ៌ខៀវមួយតែប៉ុណ្ណោះដោយចូលទៅកាន់ Window > Channels បន្ទាប់មក Right Click លើ Layer Blue យកពាក្យ Duplicate Channel ហើយកំណត់ដូចរូបខាងក្រោមរួច Save ជារូប មួយថ្មីទៀតដោយចុចលើប៊ូតុង Ok ៖




បន្ទាប់មកសូមកំណត់នូវ Gaussian Blur ទំហំ 2 pixel ទៅលើរូបថ្មីដែលបានជ្រើសរើសពី Channels ខាងលើ ដោយចូលទៅ Filter > Blur > Gaussian Blur



ក្រោយមកទៀតសូមចូលទៅធ្វើការកែប្រែពន្លឺខ្លះដើម្បីឲ្យមានលក្ខណៈស្រស់ស្អាតដោយចូលទៅ Image > adjustments > auto levels ឬចុច Ctrl +L កំណត់តាមរូបរួចសូមចុច Save (adisplace.psd)




សូមកំណត់ Layer Blending Mode ជាប្រភេទ Multiply នោះលោកអ្នកនឹងទទួលបាននូវលទ្ធផលដូចខាងក្រោម៖



# 03

បង្កើត Layer ថ្មីឈ្មោះ Bark រួចបើករូបសំបកឈើដោយឈរលើ Layer Bark រួចចូលទៅកាន់ Filter > Distort > Displace បន្ទាប់មកសូមធ្វើការកំណត់តំលៃទៅតាមរូបខាងក្រោមរួចចុចប៊ូតុង Ok ៖




ឈរលើ Layer Bark ដដែល ក្រោយមកសូម Brow ទៅរកទីតាំងរបស់ File adisplace.psd ដែលយើងបានធ្វើរួចជាស្រេច បន្ទាប់មកសូមចុចប៊ូតុង Open ៖




# 04

សូមធ្វើការចំលង Layer Bark ចំនួនពីរ ដោយទីមួយកំណត់ Mode ជា Multiply ព្រមជាមួយ Opacity 100% និងទីពីរកំណត់ Mode ជា Normal ព្រមជាមួយនឹង Opacity 40 % សូមមើលរូបខាងក្រោម៖




# 05

ចុចលើ Layer Face ពីដងដើម្បីបង្កើត Selection រួចឈរលើ Layer Bark Normal 40% បន្ទាប់មកសូមចូលទៅកាន់ Layer > Layer Mask > Reveal selection ៖




ចំពោះ Layer Bark Multiply 100% ក៏អនុវត្តន៍ដូចគ្នាទៅនឹង Layer Bark Normal 40% ដែរ គឺចូលទៅLayer > Layer Mask > Reveal selection ៖




ឈរលើ Layer Bark Normal 40% រួចសូមយកម៉ៅចុចលើMask ដែលមាន Background ពត៌ខ្មៅ បន្ទាប់មកសូមចុច Delect Key ។ ចំពោះ Layer Bark Multiply 100% ក៏អនុវត្តន៍ដូចគ្នាទៅនឹង Layer Bark Normal 40% ផងដែរ៖




សូមឈរលើ Layer Bark Multiply 100% រួចប្រើ Pen tool ដោយគូរលើនៅលើ ភ្នែក និង មាត់ បន្ទាប់មកសូមធ្វើការ Right Click លើគំនុស Pen tool ដែលបានគូររួច យកពាក្យថា Make Selectio ដើម្បី Load Selection ៖




**06** សូមចូលទៅកាន់ Layer > New Adjustment Layer > Curves រួចសូមចាក់ Background នៃ Curves ពណ៌ខ្មៅ ព្រមទាំងកែប្រែតំលៃមួយចំនួន ដូចខាងក្រោម៖







## 07

ចុចដោះភ្នែកលើ Layer Bark បន្ទាប់មកសូមឈរលើ Layer Face រួចប្រើ Pen Tool គូរនៅក្នុងបរិវេណមាត់ បន្ទាប់មក Make Selection ហើយប្តូរទៅឈរលើ Layer Curves1 នៃ Mask ប្រើ Brush Tool កំណត់ទំហំ 15 px Opacity 16% និងដាក់ពណ៌ស ក្រោយមកយក Brush គូលើ Selection នោះ ដើម្បីមើលទៅឲ្យដូចជាមនុស្សដែលមានស្នាមជ្រួញ៖







## 08

ក្នុងជំហាននេះគឺវាហាក់បីដូចជាជំហានទី 7 ដែរ ក៏ប៉ុន្តែខុសគ្នា ត្រង់ថាយើងបែរទៅអនុវត្តន៍នៅលើត្របកភ្នែកវិញម្តង ដោយប្រើ Brush Tool និង កំណត់ដូចលក្ខ័ណនៅក្នុងជំហានទី ៧ ហើយធ្វើការគូរនៅលើត្របកភ្នែកទាំងពីរ នោះលោកអ្នកនឹងទទួលបានជារូបត្របកភ្នែកដូចខាងក្រោម៖




## 09

បង្កើត Selection ដោយចុចពីរដងនៅលើ Layer Face បន្ទាប់មកឈរលើ Layer Curves 1 ហើយចុចលើ Mask រួចប្រើ Brush tool ដោយកំណត់ពណ៌ស ទំហំ 150 px និង Opacity 16% ក្រោយមកសូមបាញ់ Brush តាម Selection នៅលើមុខ ដើម្បីឲ្យ មើលទៅដូចជាមុខមនុស្សផុសឡើង៖




ដើម្បី Deselect សូមចុច Select > Deselect ឬ Ctrl + D ឈរលើ Layer Curves 1 ហើយចុចលើ Mask បន្ទាប់មកសូមចូលទៅកាន់ Filter > Blur > Gaussian Blur ដោយកំណត់ទំហំស្មើនឹង 0.6 px ៖




នេះគឺជាលទ្ធផលដែលលោកអ្នកនឹងទទួលបាន ៖



# 10

ធ្វើការចម្លង Layer bark ដោយកំណត់ Opacity 40 % បន្ទាប់សូមបង្កើត Layer ថ្មីមួយទៀត ដាក់ឈ្មោះថា Color ហើយចាក់ពណ៌ដូចតំលៃដែលបានកំណត់ដូចខាងក្រោម៖




ដាក់ Layer Bark copy នៅខាងលើ Layer Bark និង Layer color នៅខាងក្រោម Layer Bark សូមមើលរូបភាពខាងក្រោម៖




បន្ទាប់មកសូម Load Selection នៅលើ Layer face រួចឈរលើ Layer Curves 1 ហើយចុចលើ Mask ក្រោយមកចូលទៅកាន់ Select > Inverse ក្រោយមកទៀតចូល Select > Modify > Expand ដោយកំណត់ទំហំ 2 px ដូចរូប៖




ឈរលើ Layer Curves 1 ដដែល ហើយធ្វើការចាក់ពណ៌ទៅលើ Mask ប៉ុន្តែផ្នែកខាងក្រៅនៃរូបមុខមនុស្សដោយកំណត់ពណ៌ដូចខាងក្រោម៖




សូម Deselect ដោយចុច Ctrl + D ដើម្បីដោះ Selection ៖




# 11

ធ្វើការបង្កើតនូវ Curves ថ្មីមួយទៀតដោយចូលទៅកាន់ Layer > New Adjustment Layer > Curves បន្ទាប់មកកែប្រែពន្លឺធ្វើម៉េចឲ្យសមទៅតាមដែលលោកអ្នកចង់បាន៖




បន្ទាប់មកសូមចូលទៅ Layer > New Adjustment Layer > Hue/Saturation រួចកែប្រែតំលៃដូចខាងក្រោម៖




# 12

Selected រាល់ Layer ទាំងអស់ដោយចុច Selecte លើ Layer លើគេបំផុតរួចចុច Shift បន្ទាប់មកសូមចុចលើ Layer ខាងក្រោមគេបង្អស់ បន្ទាប់មកទៀតសូមចុចម៉ៅស្តាំ (Right Click) លើ Selection យកពាក្យថា Flatten image ដើម្បីធ្វើការ Convert Layers ទាំងអស់ឲ្យទៅជា Layer Background តែមួយសូមអនុវត្តន៍ដូចរូប៖




បន្ទាប់មកសូមចូលទៅកាន់ Filter > Liquify ឬ ចុច Shift + Ctrl + X បន្ទាប់មកជ្រើសរើស Bloat tool ដើម្បីធ្វើឲ្យនៅលើមុខមានលក្ខណៈដូចជា 3D នៅលើ ថ្ងាស ថ្ពាល់ ក៏ដូចជាច្រមុះជាដើម៖





## 13

ជំហាននេះសូមលោកអ្នកធ្វើការស្វែងរកនូវរូបអណ្តើកមាស និងរូបត្រួយឈើ ដោយកាត់រូបទាំងនេះដោយ Pen tool ហើយធ្វើការតុបតែងដោយបង្កើត Layer ចំនួនពីរ ដូចរូបខាងក្រោម៖




ជំហានទី ១៥៖

## 14

ធ្វើការបើករូប Logo របស់ទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យារួច Load Selection ចុច Delete Key បន្ទាប់មកទៀតឈរលើ Layer Background ចុច Ctrl + J ដើម្បី Cut នឹងបង្កើត Layer ថ្មី ៖



ក្រោយមកសូមឈរលើ Layer Logo រួចសូមចូលទៅកាន់ Layer > Layer Style > Bevel and Emboss សូមមើលរូប៖




ឈរលើ Layer Logo ដដែរ Layer > Layer Style > Drop Shadow ដើម្បីកំណត់ Affect ទៅលើ Logo បន្ថែមទៀត៖



សូមកំណត់តំលៃ File ស្មើរ 0( សូន្យ )។ រូបភាពខាងស្តាំគឺជាលទ្ធផលដែលទទួលបាន៖










ក្រោយពីការកំណត់ តំលៃ File ស្មើរ 0 (សូន្យ) លោកអ្នកក៏អាច ធ្វើការប្តូរទីតាំងនៃ Logo ទៅគ្រប់ទីកន្លែង ហើយវានៅតែចាប់ តំលៃ Background ធ្វើជាផ្ទៃរបស់វាដដែល។



# Quick Study

- វិធីសាស្រ្តងាយៗនៃការងាររដ្ឋបាល ដោយប្រើ Mail Merge ក្នុង Word 2013
- គន្លឹះងាយៗសម្រាប់កែប្រែម៉ោងនៃ Windows 8 Lock Screen
- បញ្ឈប់ការរំខាន នៃការផ្ញើ Email របស់ Facebook និង Google+ ទៅកាន់ Email Account
- វិធីសាស្រ្តបង្កើត Recovery Drive






# វិធីសាស្ត្រងាយៗនៃការងាររដ្ឋបាលដោយប្រើ Mail Merge ក្នុង Word 2013



ក្នុងការងាររដ្ឋបាលគ្រប់ស្ថាប័នមិនថារដ្ឋ ឯកជន ឬក្រុមហ៊ុនតូចធំតែងតែជ្រើសរើសយកកម្មវិធីមួយដែលជាផលិតផលរបស់ក្រុមហ៊ុន Microsoft ឈ្មោះ Microsoft Word ដោយខានពុំបាន។ ពីមួយជំនាន់ទៅមួយជំនាន់ Microsoft Word បានធ្វើការ Update ទាំង Version និងសម្ថភាពដែលបង្ករលក្ខណៈងាយស្រួលដល់អ្នកប្រើប្រាស់។ យ៉ាងណាមិញក្នុងលេខនេះដែរ ក្រុមការងាររបស់យើងនឹងធ្វើការបង្ហាញពីរបៀបប្រើ Mail Merge នៅក្នុង Microsoft Word 2013 ជូនដល់ប្រិយមិត្តដែលនិយមគាំទ្រទស្សនាវដ្ដីទីក្រុងព័ត៌មានវិទ្យា។ តើអ្វីទៅជា Mail Merge? គេប្រើក្នុងគោលបំណងអ្វី?តាមពិតទៅ Mail Merge ត្រូវបានគេប្រើសម្រាប់ធ្វើការងាររដ្ឋបាលមួយចំនួនដូចជា ការធ្វើនាមប័ណ្ណ លិខិតអញ្ជើញ ស្រោមសំបុត្រអញ្ជើញពិធីអាពាហ៍ពិពាហ៍ ដោយមានព័ត៌មានដដែលៗដូចជា ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទ ជាដើម ដោយលោកអ្នកធ្វើតែម្តងគឺបានទាំងអស់។ ដូច្នេះដើម្បីឲ្យយល់កាន់តែច្បាស់ សូមអនុវត្តន៍ជាមួយគ្នានឹងក្រុមការងាររបស់យើងដែលមានជាដំណាក់កាលដូចខាងក្រោម៖

**១.** បើកកម្មវិធី Micrisoft Word ដោយចូលទៅកាន់ Start > All Pro_ gram > Microsoft Office > word 2013 ឬដោយប្រើ Command Start + R > Windord > Enter ។ បន្ទាប់មកបង្កើត Table មួយដែលមាន 6 Rows 5 Columns







**២.** ធ្វើការបំពេញតម្លៃទៅតាមតម្រូវការដែលលោកអ្នកចង់បាន ប៉ុន្តែសម្រាប់ការអនុវត្តន៍របស់ក្រុមការងាររបស់យើងមានដូចជា ID, Name, Sex, Position, Image សូមមើលរូប៖




បន្ទប់មកសូមរក្សាទុកនៅក្នុងទីតាំងមួយដោយដាក់ឈ្មោះ Staff ហើយ Save រួចបិទ Document នេះចុះ ដើម្បីឲ្យកាន់តែច្បាស់សូមមើលរូបខាងក្រោម៖



៣. ធ្វើការបង្កើតនូវ Document Word មួយថ្មីទៀត បន្ទាប់មកសូមធ្វើការរចនាជាទម្រង់នាមប័ណ្ណដោយឧទាហរណ៍របស់ក្រុមការងារយើងបានធ្វើការរចនារូបមួយដែលជា Logo របស់ក្រុមហ៊ុនទុកជាស្រេចហើយដូច្នេះសូមលោកអ្នក Insert រូបនោះចូលមកក្នុង Document របស់យើងដោយចូលទៅកាន់ Insert > Pictures > Brow ទៅរកទីតាំងដែលវាស្ថិតនៅបន្ទាប់មកសូមចុចប៊ូតុង Insert ជាការស្រេច៖



សូមចុចនៅលើរូបភាពនោះ បន្ទាប់មកសូមចូលទៅកាន់ Picture Toos ហើយធ្វើការកំណត់ Picture Style ជា Reflected Rounded Rectangle



បន្ទាប់មកលោកអ្នកនឹងទទួលបានលទ្ធផលដូចរូបខាងក្រោមដែលមានសណ្ឋានដូចជានាមប័ណ្ណសូមមើលរូប៖



៤. ប្រើ Text Box ដើម្បីគូជាចំណុចសម្រាប់ដាក់ទិន្នន័យទៅតាមតម្រូវការរបស់លោកអ្នកក្នុងគោលបំណងងាយស្រួលគ្រប់គ្រងទម្រង់ឲ្យមានលក្ខណៈស្រស់ស្អាតដោយចូលទៅកាន់ Insert > Text Box > Draw Text Box រួចធ្វើការគូរជាការស្រេច៖



សូមលោកអ្នកមើលលទ្ធផលដែលទទួលបានដូចរូបភាពខាងក្រោម៖



សូមធ្វើការដោះបន្ទាត់ចេញពី Text Box ដោយចុចនៅលើ Text Box ទាំងអស់ រួចចូលទៅកាន់ Format > Shap Outline > No Outline សូមមើលរូបខាងក្រោម៖



៥. សូមធ្វើការ Start Mail Merge ដោយចូលទៅកាន់ Mailings > Select Recipients > Use an Existing List > Brow ទៅរក File Staff ដែលផ្ទុកទិន្នន័យ ហើយចុច Open ជាការស្រេច៖



បន្ទាប់ពីបានធ្វើការ Start Mail Merge រួចមកសូមលោកអ្នកដាក់ Cursor ទៅក្នុង Text Box Name រួចចូលទៅកាន់ Mailings > Insert Merge Field > Name ៖



ធ្វើដូចខាងលើដដែលៗ រហូតទាល់តែអស់តម្រូវការដែលមាននៅក្នុងនាមប័ណ្ណទាំងអស់ សូមមើលរូបភាពខាងក្រោម៖



៦. ក្រោយពីលោកអ្នកបានធ្វើការអនុវត្តន៍ជាជំហានៗដូចក្រុមការងាររបស់យើងខាងលើលោកអ្នកនឹងទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត។ លោកអ្នកអាចមើលលទ្ធផលបានដោយគ្រាន់តែចុច Preview Results ៖



នៅពេលដែលលោកអ្នកចុចប៊ូតុង Next Recode នោះវានឹងធ្វើការទាញទិន្នន័យពី Row បន្ទាប់ដែលមាននៅក្នុង Table នៃ staff File សូមមើលរូបដើម្បីឲ្យកាន់តែច្បាស់៖



សូមបញ្ជាក់ដែលថានៅពេលយើងធ្វើការ Print ប្រសិនបើលោកអ្នកមានទិន្នន័យនៅក្នុង Table នៃ Staff File 100 Record នោះវានឹងធ្វើការ Print ទាំងអស់ដោយពុំចាំបាច់លោកអ្នកធ្វើការបង្កើតនូវនាមប័ណ្ណនេះដដែលៗរហូតដល់ 100 ដងនោះទេ។

Question & Answer
QUESTION & ANSWER
ប្រសិនបើមានបញ្ហាសូមទូរស័ព្ទមកកាន់លេខ៖ 012 999 140
We live with technology
IT City Magazine

Quick Study

# គន្លឹះងាយៗសម្រាប់កែប្រែម៉ោង នៃ Windows 8 Lock Screen



ប្រសិនបើលោកអ្នកប្រើ Windows 8 នៅពេលដែលលោកអ្នកចុច Lock Screen ឬក៏ចុច Start + L នោះតើលោកអ្នកនឹងឃើញអ្វីកើតឡើង ? បាទពិតណាស់កុំព្យូទ័រ Windows របស់លោកអ្នកប្រាកដជា Lock Screen ហើយមែនទេ? ម្យ៉ាងវិញទៀតវានឹងបង្ហាញព្រមជាមួយនូវ ម៉ោង ថ្ងៃខែ និងអាកាសធាតុជាដើម។ តើការបរិច្ឆេតនៃម៉ោងរបស់លោកអ្នកមានទម្រង់យ៉ាងដូចម្តេច? ជាធម្មតាវាប្រាកដជាចាប់យកតម្លៃដូចទៅនឹងទម្រង់នៃ Taskbar របស់លោកអ្នកមិនខាន។ ប៉ុន្តែមិនថ្វីទេលោកអ្នកអាចធ្វើការកែប្រែទម្រង់របស់វាបានយ៉ាងងាយបំផុត។




ចំពោះការកែប្រែទម្រង់របស់ម៉ោងលោកអ្នកអាចចូលទៅ Control Panel ដែលអនុញ្ញាតឲ្យយើងអាចធ្វើការកែប្រែបានយ៉ាងងាយស្រួលនៃ Lock Screen របស់ម៉ោង និងការបរិច្ឆេតនៃកុំព្យូទ័ររបស់យើង។ ម្យ៉ាងវិញទៀតលោកអ្នកក៏អាចធ្វើការកែប្រែបានតាមរយៈ Registry




ដើម្បីចូលទៅកាន់ Regedit សូមចុច Start + R > regedit > Enter បន្ទាប់មក Windows នឹងបង្ហាញ Dialog Registry Editor ដូចរូបខាងក្រោម៖




បន្ទាប់មកសូមចូលទៅកាន់ទីតាំងនៃ LocaleInfo ដោយចុចលើ HKEY_LOCAL_MACHINE\SOFTWARE\Microsoft\Windows\CurrentVersion\ SystemProtectedUserData\S-1-5-21-[unique ID]\ AnyoneRead\LocaleInfo ក្រោយមកសូម Right Click លើ LocaleInfo យលពាក្យថា Permissions មើលរូប៖







បន្ទាប់មកសូមធ្វើការផ្តល់សិទ្ធិទៅឲ្យអ្នកប្រើប្រាស់ Full Control ដើម្បីអនុញ្ញាតឲ្យអ្នកប្រើប្រាស់មានសិទ្ធិគ្រប់គ្រាន់សម្រាប់ធ្វើការកែប្រែតម្លៃទៅលើ Regedit ដោយគ្រាន់តែធីកទៅលើ Full Control បន្ទាប់មកសូមចុចប៊ូតុង Ok ជាការស្រេច៖




ចំណុចនេះលោកអ្នកសូមចុចពីរដងនៅលើ TimeFormat នោះវានឹងលេចឡើងនូវ Dialog Box មួយសម្រាប់លោកអ្នកអាចកែប្រែទម្រង់ម៉ោងទៅតាមដែលលោកអ្នកចង់បាន នៅក្នុង TextBox Value data បន្ទាប់មកសូមចុចប៊ូតុង Ok




បន្ទាប់ពីលោកអ្នកបានអនុវត្តន៍ទៅតាមការណែនាំរបស់ក្រុមការងារយើងនោះលោកអ្នកនឹងទទួលបានទម្រង់ម៉ោងថ្មីនៅពេលដែលលោកអ្នកធ្វើការ Lock Screen ដូចលទ្ធផលនៃរូបខាងក្រោម ៖







# បញ្ឈប់ការរំខាន នៃការផ្ញើ Email របស់ Facebook និង Google+ ទៅកាន់ email Account



ជារឿយៗលោកអ្នកដែលជាប្រិយមិត្តនៃបណ្តាញសង្គម Facebook និង Google+ កំពុងតែមានការរំខានដល់លោកអ្នកមួយចំនួនបូករួមទាំងក្រុមការងារយើងផងដែរ តាមរយៈការផ្ញើសារអេឡិចត្រូនិចចូលក្នុងអាសយដ្ឋានអ៊ីម៉ែលរបស់លោកអ្នកណាស់មែនទេ? តាមពិតទៅ វាពិតជាមានសារៈសំខាន់ណាស់សម្រាប់លោកអ្នកដែលមានបំណងចង់បញ្ឈប់ការរំខានពីការផ្ញើ Email របស់ Facebook និង Google+ មកកាន់ Email Account ឲ្យដឹងពីការផ្លាស់ប្តូរថ្មីៗ ពីមិត្តភក្តិរបស់អ្នកតាមរយៈការផុសរបស់ពួកគេ ។

ចុះបើលោកអ្នកអនឡាញស្ទើរតែ៥ ទៅ ១០ម៉ោង ក្នុងមួយថ្ងៃនោះ តើលោកអ្នកចាំបាច់ត្រូវទទួលយកការផ្ញើសារនោះទៀតដែរទេ? ចម្លើយ ប្រាកដជាអត់ហើយ!

## * ដំណោះស្រាយដើម្បីបញ្ឈប់ការរំខាន

### ក. សម្រាប់ FACEBOOK

ជាដំបូង សូម Login ចូលទៅកាន់គណនី Facebook របស់អ្នករួចបន្តសូមចុចលើសញ្ញា Setting (*) ហើយចូលទៅកាន់ Account Settings




បន្ទាប់មកសូមចុចលើ Tab Notification ដែលនៅខាងឆ្វេងដៃរបស់លោកអ្នកនោះវានឹងលេចចេញនូវ Form មួយដូចរូបខាងក្រោម៖




សូមលោកអ្នកបន្ត ចុចលើ Edit ត្រង់ Email រួចធ្វើការកំណត់ថា តើលោកអ្នកចង់ឲ្យ Facebook ផ្ញើទៅលោកអ្នកនូវត្រង់ចំនុចណាខ្លះ ឬអាចធ្វើតាមរូបខាងក្រោមជាការស្រេច៖




## ខ. សម្រាប់ GOOGLE+

សម្រាប់ Google Plus វិញលោកអ្នក អាចបិទការផ្ញើសាររំខានចូល Inbox Gmail របស់អ្នកបានដោយចូលផ្ទាល់ទៅកាន់ https://www.google.com/settings/plus




បន្ទាប់មក សូម Scroll ចុះក្រោម រហូតដល់ត្រង់ចំណុច Receive Notifications រួចលោកអ្នកអាចជ្រើសរើសជម្រើសណាមួយដែលលោកអ្នកមិនចង់ទទួលបានសារចូលក្នុង Inbox អ្នក ។




ក្រោយពីលោកអ្នកបានអនុវត្តន៍ដូចដែលក្រុមការងាររបស់យើងបានធ្វើការបង្ហាញខាងលើនោះ រាល់ការរំខានពីសំណាក់សារអេឡិចត្រូនិចពិតជាគ្មានការរំខានដល់ Account Email របស់លោកអ្នកទៀតហើយ៕



ជាទូទៅ កាលដែលលោកអ្នកប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រជារៀងរាល់ថ្ងៃ នោះច្បាស់ជាជៀសមិនផុតឡើយពីការកើតមានឡើងនូវបញ្ហាផ្សេងៗ។ ហើយ ដើម្បីជាការសម្រួល និងដោះស្រាយបញ្ហាចៃដន្យរបៀបនេះបានអ្នកប្រើប្រាស់គួរតែបង្កើត Recovery Drive មួយឡើងព្រោះថាការធ្វើបែបនេះបានផ្តល់ ឲ្យអ្នកប្រើប្រាស់នូវយុទ្ធសាស្ត្រដ៏ល្អក្នុងការ Boot ម៉ាស៊ីនកុំព្យូទ័ររបស់លោកអ្នកឡើងវិញ រួចហើយទើបចាប់ផ្តើមដំណើរការទៅដល់ដំណាក់កាល Recovery Tool តែម្តង។ ផ្ទុយមកវិញដើម្បីអាចធ្វើការបង្កើត Recovery Drive បានជាបឋមលោកអ្នកត្រូវចូលទៅកាន់ Start Search រួចចុចលើមុខងារ "Settings" និងបន្តវាយពាក្យ "Recovery ឬ Recover" ចូលក្នុងប្រអប់ Settings បន្ទាប់មកសូមជ្រើសរើសយក "Create a recovery drive" ។




ជាមួយគ្នានេះដែរ Recovery Drive Creator នឹងចាប់ផ្តើមបង្ហាញលោកអ្នកជាលក្ខណៈ Desktop-based Wizard ដែលនៅក្នុងផ្ទាំងនោះមានភ្ជាប់មកនូវ Option អនុញ្ញាតឲ្យអ្នកប្រើប្រាស់អាចធ្វើការបង្កើត Recovery Drive បានយ៉ាងងាយ ។




ក្រោយពីលោកអ្នកចុចលើប៊ូតុង "Next" ពេលនោះការភ្ជាប់ទៅកាន់ USB Flash Drive នឹងកើតឡើងភ្លាម។ ម្យ៉ាងទៀតលោកអ្នកក៏នឹងបានឃើញផងដែរនូវ Drives ទាំងអស់ដែលនៅជាប់ម៉ាស៊ីន កុំព្យូទ័រនោះដូចជា CD-RW ឬ DVD-R ជាដើម។ បន្ថែមលើនេះទៅទៀតលោកអ្នកក៏អាចជ្រើស Drives ទាំងនោះជំនួសឲ្យ USB Flash Drive ក៏បានគឺលោកអ្នកគ្រាន់តែចុចលើមុខងារ "Create a system repair disk with a CD or DVD" ។




បន្ទាប់មកសូមចាប់ផ្តើមធ្វើការ Select ទៅលើ Drive ណាមួយដែលលោកអ្នកត្រូវការ Recovery Drive រួចហើយបន្តចុចលើប៊ូតុង "Next" ភ្លាមនោះឃើញថា Recovery Wizard នឹងបង្ហាញបញ្ជាក់លោកអ្នកថាអ្វីៗនៅក្នុង Drives នឹងត្រូវបានលុបចោលទាំងស្រុង បន្ទាប់មកលោកអ្នក ចុចលើប៊ូតុង "Create" ។




ភ្លាមនោះ Recovery Drive Wizard នឹងចាប់ផ្តើមបង្ហាញឡើងព្រមជាមួយដំណើរការនៃការ Formatting Drive ផងដែរ ហើយវានឹងធ្វើការថតចម្លង Utilities, Tool រួមជាមួយ Files ជាច្រើនផ្សេងទៀតដែលជាតម្រូវការក្នុងការបង្កើត Recovery Environment ៕



# ប៉ិនប្រសព្វក្នុងការចែក PARTITION ជាមួយ EASEUS PARTITION MASTER SERVER ជំនាន់ថ្មី








កាលពីលេខមុន ទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាបានង្ហាញទៅដល់ប្រិយមិត្តយ៉ាងលម្អិតទាក់ទងទៅនឹងការបង្កើត Auto Play នៅ លើបន្ទះ CD & DVD រួចមកហើយ។ ដោយឡែកនៅក្នុងការចេញផ្សាយលេខនេះផងដែរ ក្រុមការងារនៃទស្សនាវដ្ដីយើងនឹងពាំនាំលើកយកមកបង្ហាញនូវចំណេះដឹងថ្មីៗក៏ដូចជាបទពិសោធន៍ល្អៗ។ ទាក់ទងទៅនឹង Partition របស់ Hardisk Drive នៅក្នុងម៉ាស៊ីនកុំព្យូទ័រដោយក្នុងនោះរួមមានការបែងចែក គ្រប់គ្រង បង្កើតនូវ Partition HDD ។ និយាយពីលក្ខណៈពិសេសដែលកម្មវិធីនឹងត្រូវលើកយកមកបង្ហាញនេះ គឺបានផ្ដល់នូវសារៈប្រយោជន៍ដ៏ច្រើន និងដំណោះស្រាយដ៏ល្អបំផុត។ ជាងនេះទៅទៀតនោះបានសិក្សាបង្កើតផ្ដល់នូវភាពងាយស្រួលទៅលើការប្រើប្រាស់ និងភាពសំបូរបែបនៃសមត្ថភាពទាំងស្រុងទៅលើ Hardisk ដូចជា មុខងារពន្លានូវ NTFS system partition ដោយមិនចាំបាច់ reboot ម៉ាស៊ីនកុំព្យូទ័រ។ មុខងារ Merge partitions ច្របាច់បញ្ចូលនូវ Partition ទាំងអស់ឲ្យទៅជា Partition តែមួយ មុខងារបំប្លែង (Convert) ប្រភេទ File System ពី FAT ទៅ NTFS និងជាពិសេសប្រើប្រាស់ទៅនឹងជំនាន់ Microsoft Windows XP, Vista, 7 និង 8 ថែមទៀតផង៕

## ១. របៀបដំណើរការកម្មវិធី

បន្ទាប់ពីលោកអ្នកបានដំឡើងកម្មវិធីរួចរាល់ហើយ សូមចុចទៅលើម៉ឺនុយ Start > All Programs > easeUS Partition Master 9.2.1 Server Edition> easeUS Partition Master 9.2.1 Server Edition ពេលនោះផ្ទាំកម្មវិធីអនុវត្តន៍នឹងលេចចេញឡើងដូចរូបខាងក្រោម:



## ២. វិធីសាស្ត្រនៃការប្រើប្រាស់

ជាដំបូងក្រុមការងារសូមបង្ហាញពីជំហាននីមួយៗរបស់កម្មវិធី ទៅលើ Hardisk ដូចខាងក្រោម:

+ បង្កើត Partition ថ្មី

ដើម្បីបង្កើតនូវទំហំ ឬក៏ Partition ថ្មីចេញពី Partition ដែលមានទិន្នន័យហើយមិនបានបង់ទិន្នន័យនោះដំណាក់កាលដំបូងត្រូវតែដឹងយ៉ាងច្បាស់នូវទំហំទំនេររបស់ Partition ដែលត្រូវបង្កើត ហើយ Partition ដែលបង្កើតថ្មីត្រូវមានទំហំតូចជាទំហំទំនេរនៃទំហំ Partition ដែលត្រូវយកមកបង្កើតដោយ Right+Click លើ Partition នោះរួចយកពាក្យ Resize/Move partition



បង្ហាញផ្ទាំង Resize/Move partition



នៅក្នុងផ្ទាំង Resize/Move partition ហើយត្រង់ចំណុច Unallocated Space After ត្រូវវាយតម្លៃលេខនៃទំហំ Partition ដែលត្រូវបង្កើតថ្មីដោយគិតជា MB។ ចំណុចនេះផងដែរក្រុមការងារយើងសូមជ្រើសយកទំហំ 5 GB = 5120 MB ដោយយកទំហំសរុបទាំងអស់របស់ Partition Size 19994.9 ដកនូវទំហំ partition ថ្មីដែលត្រូវបង្កើតគឺ 19994.9 - 5120 = 14874.9 យកទៅវាយនៅត្រង់ប្រលោះ Partition Size ដូចរូប។ ខ្នាតឯកតា 1GB = 1024MB។




បន្ទាប់មកចុចលើប៊ូតុង OK ដែលស្ថិតនៅផ្នែកខាងក្រោម




ចុចលើប៊ូតុង OK រួចនៅលើផ្ទាំងកម្មវិធីអនុវត្តយើងដដែលនឹងលេចឡើងនូវ Partition ថ្មីមួយដែល Partition ថ្មីមួយនោះមាន ទំហំ 5 GB ហើយ Right+Click លើ Partition ថ្មីនោះយកពាក្យ Create Partition



បង្ហាញផ្ទាំង Crate Partition

+ Partition Label គឺជាឈ្មោះរបស់ Partition ថ្មី
+ Create As ជ្រើសយក Logical
+ File System ជ្រើសយក NTFS
+ Drive Letter តាមតម្រូវការ
+ Cluster Size ជ្រើសយក Default

រួចចុចប៊ូតុង OK




បង្ហាញ Partition ថ្មីនៅក្នុងកម្មវិធីអនុវត្ត



បន្ទាប់ចុចប៊ូតុង Apply



ផ្ទាំងបន្ទាប់ចុចលើប៊ូតុង YES




បង្ហាញផ្ទាំងកម្មវិធីដំណើរការ




បង្ហាញផ្ទាំងក្រោយពីការបង្កើតទទួលជោគជ័យ




បង្ហាញ Partition ដែលបានបង្កើតថ្មី



+ បន្ថែមទំហំទំនេរពី Partition D (Data) ទៅកាន់ Partition C (Windows)

នៅត្រង់ដំណាក់កាលនេះក្រុមការងារយើងនឹងធ្វើការបង្ហាញដោយយកទំហំ Free Space 2 GB ពី Partition D (Data) ទៅ បញ្ចូលក្នុង Partition C (Windows)។ Right + Click លើ Partition D (Data) យកពាក្យ Resize/Move partition



នៅលើផ្ទាំង Resize/Move partition ត្រូវយកទំហំ Partition Size ទាំងអស់គិតជា MB គឺ 14880.5 MB ដកទំហំ 2 GB គិតជា MB គឺ 2048។ 14880.5 - 2048 = 12832.5 MB ហើយយកតម្លៃនោះវាយបញ្ចូលទៅក្នុងប្រឡោះ Partition Size ដូចរូប



ក្រោយពីកំណត់តាមតម្រូវការហើយ ចុចលើប៊ូតុង OK




ចុចលើប៊ូតុង OK រួចនៅក្នុងផ្ទាំងកម្មវិធីអនុវត្តនឹងលេចចេញ នូវ Partition ថ្មីមួយដែលមានទំហំ 2GB និងមាន File System (Unallocated) ដូចរូបខាងក្រោម



ត្រង់ចំណុចនេះដដែលដើម្បីបញ្ចូលទំហំទំនេរទៅក្នុង Partition C (Windows) នោះនៅផ្នែកខាងក្រោមត្រូវប្រើនូវ Cursors ដើម្បីទាញទំហំទំនេរ 2GB នោះទៅដាក់ពីខាងមុខ Partition C (Windows) ដូចរូប



បង្ហាញទំហំទំនេរ ស្ថិតនៅពីខាងមុខ Partition C (Windows)




បន្ទាប់ពីបានទំហំ Free Space ស្ថិតនៅពីខាងមុខ Partition C (Windows) ហើយនោះ ត្រូវ Right+Click លើ Partition C (Windows) នោះយកពាក្យ Resize/Move partition



នៅក្នុងផ្ទាំង Resize/Move partitio នៃផ្នែកខាងលើ ត្រូវប្រើ Cursors ដាក់ឲ្យចេញដូចរូប ⟷ រួចទាញពីស្តាំទៅឆ្វេង



បង្ហាញទំហំ Partition Size ថ្មីក្រោយពីអនុវត្ត




ចុចប៊ូតុង OK ដើម្បីសម្រេច




ចុងក្រោយចុចប៊ូតុង Apply



ផ្ទាំង Apply Change ចុចលើប៊ូតុង Yes




រួចនៅក្នុងផ្ទាំង Warning ចុចលើប៊ូតុង Yes ដើម្បី Restart




ផ្ទាំងដំណើរការ




ដំណើរការអនុវត្ត



ដំណើរការចប់ទទួលបានជោគជ័យ




បង្ហាញទំហំទំនេរ 2 GB បន្ថែមទៅលើ Partition C (Windows) ក្រោយពីអនុវត្ត



## + មុខងារ Copy Partition

Copy Partition មានន័យថា ថតចម្លងនូវឯកសារទិន្នន័យពីក្នុង Partition ណាមួយចូលទៅក្នុង Partition មួយផ្សេងទៀតឲ្យមានទិន្នន័យដូចគ្នា។ ត្រង់ចំណុចនេះដើម្បី Copy បានលុះត្រាតែ Partition ដែលត្រូវ Copy ដាក់នោះមានជាលក្ខណៈ Unallocated ដូច្នេះត្រូវបង្កើត Partition Unallocated មួយដោយ Right +Click រួចយកពាក្យ Resize/Move partition



រួចបង្កើត Unallocated Space 1024 MB រួចចុចប៊ូតុង OK




បង្ហាញ Unallocated ដែលបានបង្កើត



បន្ទាប់មក Right+Click លើ Partition ដែលត្រូវ Copy យកពាក្យ Copy Partition



បន្ទាប់មកក្នុងផ្ទាំង Partition Copy Wizard ចុចប៊ូតុង Next




ផ្ទាំងបន្ទាប់ជ្រើសយក Partition ដែលមាន File System Unallocated ដែលបានបង្កើតពីខាងលើរួចចុចប៊ូតុង Next ដើម្បី បន្ត




ចុចប៊ូតុង Apply



ចុចប៊ូតុង Yes




សកម្មភាពពេលដំណើរការ




ផ្ទាំង Finish ចុចប៊ូតុង OK




ពេលនោះយើងនឹងទទួលបាន Partition ថ្មីមួយដែលមានទិន្នន័យដូចគ្នាបេះបិទទៅនឹង Partition (E) ដែលបានថតចម្លងរួចរាល់



តាមរយៈកម្មវិធីអនុវត្ត Easeus Partition Master Server នេះ ដដែលនូវរាល់ការបង្ហាញពីមុខងារមួយចំនួនផ្សេងទៀតនឹងមានបង្ហាញនៅលេខ (162)។

(តទៅលេខ 162)

ទស្សនាវដ្តី ទីក្រុងព័ត៌មានវិទ្យា
IT CITY MAGAZINE




# របៀបរចនា Image Slideshow ដោយប្រើ HTML CSS និង Jquiry

បើយើងក្រឡេកមើលគេហទំព័រមួយចំនួនទាំងក្នុង និងក្រៅប្រទេស កំពុងតែមានវត្តមាននៅលើបណ្តាញអ៊ីនធើណែត យើងសង្កេតឃើញថាការរចនាមានលក្ខណៈខុសៗប្លែកគ្នា ក៏ប៉ុន្តែគេហទំព័រទាំងនោះគឺពុំសូវជាមើលរំលងនូវការដាក់បញ្ចូល Image Slideshow ចូលទៅក្នុងគេហទំព័ររបស់ខ្លួនឡើយ។ ការដាក់បញ្ចូលនូវ Image Slideshow ចូលទៅក្នុងគេហទំព័រគឺបានបង្កើននូវសោភ័ណ្ឌភាព ភាពរស់រវើក និងការទាក់ទាញថែមមួយ កម្រិតទៀតដល់គេហទំព័ររបស់លោកអ្នក។ Image Slideshow ត្រូវបានគេប្រើសម្រាប់ធ្វើការបង្ហាញនូវទំនិញ សេវាកម្ម និងសកម្មភាពផ្សេងៗដែលមានលក្ខណៈជា Slideshow Random។ យ៉ាងណាមិញវត្តមានរបស់ទស្សនាវដ្តីទីក្រុងពត៌មានវិទ្យាលេខ ១៦១ នេះ ក្រុមការងារនៃទស្សនាវដ្តីទីក្រុងពត៌មានវិទ្យាក៏បានធ្វើការបង្ហាញពីរបៀបរចនា ដោយធ្វើការអនុវត្តន៍ទាំងអស់គ្នាជាមួយនឹងក្រុមការងាររបស់យើងដូចខាងក្រោម៖



ជាដំបូងយើងសូមណែនាំប្រិយមិត្តទាំងអស់មេត្តាបង្កើតនូវទីកន្លែងសម្រាប់ផ្ទុកការងាររបស់យើង (Directory) ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងការងារដូចតទៅ៖

+ Folder Nº 161 : សម្រាប់ផ្ទុកការងារទាំងមូល (Project)

+ Folder images : សម្រាប់ផ្ទុករូបភាព

+ Folder css : សម្រាប់ផ្ទុក File style.css

+ Folder js : សម្រាប់ផ្ទុក File ដែលជា Library របស់ Jquery គឺ jquery.min.js និង jquery-ui.min.js ដូចរូប




***បញ្ជាក់:*** ដើម្បីបាន Library របស់ Jquery លោកអ្នកអាចទាញយកតាមរយៈ Link: http://ajax.googleapis.com/ajax/libs/jquery/1.3.2/jquery.min.js សម្រាប់ jquery.min.js និង http://ajax.googleapis.com/ajax/libs/jqueryui/1.5.3/jquery-ui.min.js សម្រាប់ jquery-ui.min.js។

ក្រោយពីយើងបានរៀបចំរចនាសម្ព័ន្ធការងាររួចរាល់ហើយ យើងចាំបាច់ត្រូវមាន Source មួយចំនួនទៀតដើម្បីបំពេញតម្រូវការឲ្យដូចលទ្ធផលដូចដែលក្រុមការងាររបស់យើងធ្វើការបង្ហាញជូន ហើយ Source ទាំងនោះមានដូចជា៖

+ background_bg.jpg : គឺជារូបភាពសម្រាប់ធ្វើផ្ទៃឲ្យ Background



+ logo_itcity.png : ជារូបភាពតំណាងឲ្យនិមិត្តសញ្ញារបស់ទស្សនាវដ្តីទីក្រុងពត៌មានវិទ្យា សម្រាប់ដាក់ជា Logo



+ image1.jpg , image1-small.jpg, image2.jpg , image2-small.jpg, image3.jpg, image3-small.jpg, image4.jpg, image4-small.jpg, image5.jpg, image5-small.jpg, selected-item.gif, transparent-bg.gif, transparent-bg.png រូបទាំងនេះត្រូវបានធ្វើជា Icons និងសម្រាប់បង្ហាញនៅក្នុង Slideshow ដោយផ្ទុកនៅក្នុង Folder images ។



## ការអនុវត្តន៍:

បន្ទាប់ពីលោកអ្នកមាន Source គ្រប់តម្រូវការដូចដែលក្រុមការងាររបស់យើងបានធ្វើការរៀបរាប់ជូនខាងលើសព្វគ្រប់អស់ហើយសូមប្រិយមិត្តធ្វើការអនុវត្តន៍ជាមួយយើងទាំងអស់គ្នាជាជំហានៗដូចខាងក្រោម៖

## ជំហានទី ១:

នេះជាជំហានដំបូងដែលយើងនឹងធ្វើការបង្កើតនូវ File មួយដោយប្រើ Code របស់ HTML សម្រាប់បង្ហាញ Content នៅលើ Browser ដោយឧបមាថា File នោះមានឈ្មោះ slider.html។

```
<html>
    <head>
        <title>Image Slide Show </title>
    </head>
<body>
<div id="logo"><img src="images/logo_itcity.png" /></div>
    <div id="featured" >
    <ul class="ui-tabs-nav">
        <li class="ui-tabs-nav-item ui-tabs-selected"
            id="nav-fragment-1">
            <a href="#fragment-1"><img src="images/
            image1-small.jpg" alt="" />
            <span>15+ Excellent High Speed Photo
            graphs</span></a>
        </li>
        <li class="ui-tabs-nav-item"
            id="nav-fragment-2">
            <a href="#fragment-2"><img src="images/
            image2-small.jpg" alt="" />
            <span>20 Beautiful Long Exposure
            Photographs</span></a>
        </li>
        <li class="ui-tabs-nav-item"
            id="nav-fragment-3">
            <a href="#fragment-3"><img src="images/
            image3-small.jpg" alt="" />
            <span>35 Amazing Logo Designs
            </span></a>
        </li>
        <li class="ui-tabs-nav-item"
            id="nav-fragment-4">
            <a href="#fragment-4"><img src="images/
            image4-small.jpg" alt="" />
```



```
                <span>Create a Vintage Photograph in
                Photoshop</span></a>
        </li>
</ul>
                <!-- First Content -->
<div id=″fragment-1″ class=″ui-tabs-panel″ style=″″>
        <img src=″images/image1.jpg″ alt=″″ />
        <div class=″info″ >
                <h2><a href=″#″ >15+ Excellent High
                Speed Photographs</a></h2>
                <p>Lorem ipsum dolor sit amet, consecte
        tur adipiscing elit. Nulla tincidunt condi
        mentum lacus. Pellentesque ut diam....
                <a href=″#″ >read more</a></p>
        </div>
</div>
                <!-- Second Content -->
<div id=″fragment-2″ class=″ui-tabs-panel
ui-tabs-hide″ style=″″>
        <img src=″images/image2.jpg″ alt=″″ />
        <div class=″info″ >
                <h2><a href=″#″ >20 Beautiful Long
                Exposure Photographs</a></h2>
                <p>Vestibulum leo quam, accumsan
                nec porttitor a, euismod ac tortor. Sed
                ipsum lorem, sagittis non egestas id,
                suscipit....<a href=″#″ >read more</a>
                </p>
```



```
        </div>
</div>
                <!-- Third Content -->
<div id=″fragment-3″ class=″ui-tabs-panel ui-tabs-
hide″ style=″″>
                <img src=″images/image3.jpg″ alt=″″ />
        <div class=″info″ >
                <h2><a href=″#″ >35 Amazing Logo
                Designs</a></h2>
                <p>liquam erat volutpat. Proin id volutpat
                nisi. Nulla facilisi. Curabitur facilisis sollici
                tudin ornare....
                <a href=″#″ >read more</a></p>
        </div>
</div>
                <!-- Fourth Content -->
<div id=″fragment-4″ class=″ui-tabs-panel
ui-tabs-hide″ style=″″>
        <img src=″images/image4.jpg″ alt=″″ />
        <div class=″info″ >
                <h2><a href=″#″ >Create a Vintage
                Photograph in Photoshop</a></h2>
                <p>Quisque sed orci ut lacus viverra
                interdum ornare sed est. Donec porta,
                erat eu pretium luctus, leo augue
        sodales....
                <a href=″#″ >read more</a></p>
        </div>
</div>
</div>
</div>
</body>
```

</html>

បន្ទាប់ពីលោកអ្នកបានសរសេរ Code html ដូចក្រុមការងារយើងខាងលើរួចមក លោកអ្នកនឹងទទួលបានលទ្ធផលដូចរូបខាងក្រោម៖




## ជំហានទី ២:

នេះជាជំហានបន្ទាប់សម្រាប់ធ្វើការរៀបចំរាល់ Content នៃគេហទំព័ររបស់យើងឲ្យមានភាពស្រស់ស្អាតទៅតាមចំណង់ចំណូលចិត្ត និងសេចក្តីត្រូវការ។ រាល់ការរចនាគេហទំព័រ ពិតជាពុំអាចខ្វះនូវ CSS បានឡើយសម្រាប់តុបតែងលំអរទម្រង់របស់ Page ។ ដូច្នេះលោកអ្នកត្រូវបង្កើត File មួយឈ្មោះ style.css ហើយផ្ទុកនៅក្នុង Folder CSS រួចសរសេរ Code នៅក្នុង File នោះដូចខាងក្រោម៖

```
body{
	background-image:url(../images/background_bg.jpg);
}
#logo{
	width:457px;
	margin-left:auto;
	margin-right:auto;
	margin-top:50px;
}
#featured{
	width:400px;
	padding-right:250px;
	position:relative;
	border:5px solid #ccc;
	height:250px;
	background:#fff;
	margin-top:50px;
	margin-left:auto;
	margin-right:auto;
}
#featured ul.ui-tabs-nav{
	position:absolute;
	top:0; left:400px;
	list-style:none;
	padding:0; margin:0;
	width:250px;
}
#featured ul.ui-tabs-nav li{
	padding:1px 0; padding-left:13px;
	font-size:12px;
	color:#666;
}
#featured ul.ui-tabs-nav li img{
	float:left; margin:2px 5px;
```



```
    background:#fff;
    padding:2px;
    border:1px solid #eee;
}
#featured ul.ui-tabs-nav li span{
    font-size:11px; font-family:Verdana;
    line-height:18px;
}
#featured li.ui-tabs-nav-item a{
    display:block;
    height:60px;
    color:#333;  background:#fff;
    line-height:20px;
}
#featured li.ui-tabs-nav-item a:hover{
    background:#f2f2f2;
}
#featured li.ui-tabs-selected{
    background:url('../images/selected-item.gif') top left no-re-
peat;
}
#featured ul.ui-tabs-nav li.ui-tabs-selected a{
    background:#ccc;
}
#featured .ui-tabs-panel{
    width:400px; height:250px;
    background:#999; position:relative;
}
#featured .ui-tabs-panel .info{
    position:absolute;
    top:180px; left:0;
    height:70px;
    background: url('../images/transparent-bg.png');
}
#featured .info h2{
    font-size:18px; font-family:Georgia, serif;
    color:#fff; padding:5px; margin:0;
    overflow:hidden;
}
#featured .info p{
    margin:0 5px;
    font-family:Verdana; font-size:11px;
    line-height:15px; color:#f0f0f0;
}
#featured .info a{
    text-decoration:none;
    color:#fff;
}
#featured .info a:hover{
    text-decoration:underline;
}
#featured .ui-tabs-hide{
    display:none;
}
```

ក្រោយពីលោកអ្នកបានសរសេរ Code ដូចដែលក្រុមការងាររបស់យើងបានធ្វើការបង្ហាញជូនដូចខាងលើ នោះយើងនឹងទទួលបាននូវទម្រង់ Interface នៃ Image Slide Show យ៉ាងស្រស់ស្អាត់ដូចរូបខាងក្រោមនេះ៖






## ជំហានទី ៣:

នេះជាជំហានចុងក្រោយដែលយើងត្រូវប្រើនូវភាសា Jquery សម្រាប់បន្ថែម Animation ដើម្បីឲ្យ Slide Show មានសភាពរស់រវើកដោយការផ្លាស់ប្តូររូបភាពពីមួយទៅមួយជាស្វ័យប្រវត្តិមានលក្ខណៈ Ramdom និងអាចចុចបានផងដែរ គ្រាន់តែសរសេរ Code នៅក្នុង Tag <head>T</head> ដូចខាងក្រោមជាការស្រេច៖

```
<script type=″text/javascript″ src=″js/jquery.min.js″ ></script>
<script type=″text/javascript″ src=″js/jquery-ui.min.js″ ></script>
<script type=″text/javascript″>
    $(document).ready(function(){
        $(″#featured > ul″).tabs({fx:{opacity: ″toggle″}}).tabs(″rotate″, 5000, true);
    });
</script>
```

ខាងក្រោមនេះគឺជាលទ្ធផលដែលយើងទទួលបានក្រោយពីបានអនុវត្តន៍នូវជំហានខាងលើ៖












www.itcity.com.kh

# ADD-ONS



## 1 Adblock for Youtube មុខងារបិទ Advert វីដេអូ :

តើលោកអ្នកមានភាពធុញថប់ជាមួយការឃោសនាផ្សាយលក់របស់ក្នុងវីដេអូដែលមាននៅលើ Youtube ដែររឺទេ?

ពេលនេះលោកអ្នកអស់កង្វល់ជាមួយបញ្ហានេះទៀតហើយដោយគ្រាន់តែដំឡើងកម្មវិធី Adblock for Youtube ភ្លាម គ្រប់ Pre-Roll Ads នៅលើ Youtube គឺត្រូវបិទជារៀងរហូត។ Adblock វាធ្វើការដកចេញការផ្សាយពាណិជកម្មវីដេអូមុនពេលបង្ហាញវីដេអូរបស់លោកអ្នក។




## 2 Screenleap for Gmail មុខងារចែករំលែក Screen ពី Gmail:

សម្រាប់មុខងារមួយនេះលោកអ្នកអាចចែករំលែលអេក្រង់ (Screen) បានភ្លាមៗពីខាងក្នុង Gmail។ ចាប់ផ្តើមចែករំលែកនូវអេក្រង់របស់លោកអ្នកជាមួយនឹងការចុចតែមួយដងគត់ដោយពុំចាំបាច់ចាកចេញពី Gmail។ ការចាប់ផ្តើមចែករំលែករបស់លោកអ្នកចេញពី Gmail ក្នុងរយៈពេលតិចជាង 5 វិនាទី ( ត្រូវការ Java ដើម្បី Share)។




## 3 Download Album រូបភាពក្នុង Facebook ជាមួយ facepaste:

ចំពោះការប្រើប្រាស់មុខងារ Add-On នេះ លោកអ្នកគ្រាន់តែ Right Click ក្នុងទំព័រ បន្ទាប់មកចុច “Download Facebook album(s)”។ លោកអ្នកអាចធ្វើបែបនេះនៅក្នុង Album រូបភាពមួយ ឬរូបភាពមួយ “Photos of You” និងរូបភាពទាំងអស់ “Photos” ក្នុងគេហទំព័ររបស់លោកអ្នក។ លោកអ្នកអាច Download បានច្រើន Albums ពីអ្នកប្រើ ប្រាស់ដោយធ្វើបែបនេះនៅលើទំព័រ “Albums”។ លោកអ្នកក៏អាច Download វីដេអូក្នុង Albums ដូចរូបភាពដែរ។




## 4 Troll Faces សម្រាប់ Facebook Chat:

Troll Faces គឺជា Add-On ដែលបន្ថែមនូវ Troll Faces ដ៏មានភាពពេញនិយមទៅក្នុងផ្ទាំង Facebook chat ដែលអាចឲ្យលោកអ្នកប្រើប្រាស់បានកាន់តែច្រើនរូបភាពយ៉ាងងាយស្រួល។ ដូច្នេះលោកអ្នកមានភាពងាយស្រួលប្រើ Troll Faces ខណៈពេលកំពុងជជែកកម្សាន្តជាមួយមិត្តភ័ក្តបានយ៉ាងសប្បាយរីករាយ។



# តើមានអ្វីប្លែកសម្រាប់

# Microsoft Office 2013 ?




ចំពោះការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ននេះមានការជឿនលឿនខ្ពស់គ្រប់វិស័យទាំង Hardware Software និងបច្ចេកវិទ្យានានាជាច្រើនទៀត។ ការវិវត្តន៍ទាំងនោះសុទ្ធតែផ្តល់ភាពងាយស្រួល រហ័ស និងចំណេញពេលវាលាក្នុងការធ្វើការងាយដល់អ្នកប្រើប្រាស់ឲ្យទទួលបាននូវប្រសិទ្ធភាពការងារខ្ពស់ ព្រមទាំងមានទំនុកចិត្ត។ ក្នុងចំណោមការអភិវឌ្ឍន៍ទាំងនោះក៏មានកម្មវិធី Microsoft Office ក៏ត្រូវបានវិវត្តន៍ទៅមុខកាន់តែពិសេសក្នុងការបម្រើការងារជូនលោកអ្នកជាមួយមុខងារ និងគុណសម្បត្តិរបស់វា នោះគឺ Microsoft Office 2013។ ជាងនេះទៅទៀតដើម្បីឲ្យកាន់តែជាក់ច្បាស់ថាវាមានអ្វីប្លែកចំពោះការបង្ហាញខ្លួនថ្មីនេះ សូមធ្វើការតាមដានទាំងអស់គ្នា។

## ភាពទូទៅរបស់ Office 2013 :

នេះគឺជាសារៈប្រយោជន៍មួយនៃ Microsoft Office 2013 ដែលដំណើការគ្រប់វិធីតាមតែអាចធ្វើបាន។

## Cloud syncing:

សម្រាប់វានេះគឺមានភាពល្អច្រើននូវមូលដ្ឋានរបស់ Office 2013។ គ្រប់ឯកសាររបស់លោកអ្នកស្វ័យប្រវត្តិចំពោះការ Save ទៅកាន់ SkyDrive folder នៅលើ Desktop មានន័យថាលោកអ្នកអាចចូលទៅកាន់ពួកវាពីឧបករណ៍នានារបស់លោកអ្នក។ លើសពី នេះ លោកអ្នកអាច Send ក្រៅ Link ដោយផ្ទាល់ ពី SkyDrive ពេលដែលកំណត់កម្រិតនៃការកែប្រែសិទ្ធនៅពេលលោកអ្នកត្រូវការ Share ឯកសារ (Document) ជាមួយមិត្តភ័ក្ត និងអ្នករួមការងារ។ ប្រសិនបើមនុស្សដែលលោកអ្នក Send ទៅមិនមាន Office 2013 វាមិនមានជាបញ្ហានោះទេ។ ដោយគ្រាន់តែចុចម្តងនៅលើ Link ខណៈនោះវាបើកឡើងនូវ Browser (Online) សម្រាប់វាដើម្បីអានបានភ្លាមៗ។

## Word 2013:

វាមើលទៅមានអារម្មណ៍ថាមានភាពដឹកនាំចំពោះវិធីសាស្រ្ត រួមជាមួយការផ្លាស់ប្តូរចំពោះពាក្យ។ តើមានចំនួនច្រើនប៉ុណ្ណាដែលអាចឲ្យចំនួនមួយបន្ថែមទៅកាន់ការជ្រើសរើសព័ត៌មានពាក្យនៅចុងបញ្ចប់ក្នុងមួយថ្ងៃ? Office 15 ឬ 2013 អាចពឹងពាក់ជាមួយនាម (Nomenclature) ដែលលោកអ្នកចូលចិត្តរក្សាទុកទ្រង់ទ្រាយ Ribbon Style រួមជាមួយ File View ប្រភេទការជ្រើសរើសការត្រដាងមកក្រៅនីមួយៗ ឆ្លងកាត់អេក្រង់ ដូចលោកអ្នកចុចនៅលើគ្រប់ Tab។ វាមានមកជាមួយ Layout Preview និង Share ជាកន្លែងដែលវត្ថុចាប់ផ្តើមដើម្បីទទួលបានការចាប់អារម្មណ៍។

## វិធីនៃការអានៈ

គ្រាន់តែចុចនៅលើ View tab រួចហើយលោកអ្នកនឹងឃើញតារាង Read Mode ដំបូងបន្ទាប់មក នឹងឃើញជាបន្តបន្ទាប់គ្រប់ការបង្ហាញផ្សេងៗតាមធម្មតា។ Read Mode ដំណើរការដូចជាស្តេចនៃ Slide Show ពីទំព័ររបស់លោក អ្នក រួចវាធ្វើការបំបែកអត្ថបទរបស់លោកអ្នកទៅ ក្នុង Column ដោយស្វ័យប្រវត្តដើម្បីផ្តល់ឲ្យវាមើលទៅមិនគួរឲ្យជឿ។ វាមានភាពងាយស្រួលអានយ៉ាងពិតប្រាកដ។

## Object Zoom:

មួយក្នុងចំណោមមុខងារ Read Mode លោកអ្នកអាច double click នៅលើ Object ដែលបានបញ្ចូល។ ដូច្នេះដូចជា Table Chart-But រូបភាព និងវីដេអូ ឥឡូវធ្វើការបំបែកចំពោះការបិទឲ្យមានទំហំពេញអេក្រង់នៅលើតម្រូវការនិងអនុញ្ញាតមិនត្រឹមតែការបង្ហាញ ពួកវានោះទេ ប៉ុន្តែអាចធ្វើអន្តរកម្មជាមួយពួកវាក្នុងបញ្ហាទំនាក់ទំនងនៃភាពយន្ត។

## ការអានបន្តៈ

ជាមួយ SkyDrive ដែលមាននៅក្នុង helm ដូចជាចំណុចនៃការរក្សាទុកការបង្កើតនូវគំនិតនេះគឺសម្រាប់ Resume នូវការអានរបស់ឯកសាររបស់លោកអ្នកនៅលើទំហំថ្មី។ វាមិនត្រឹមតែអាចឲ្យលោកអ្នកទាញយកពីកន្លែងដែលលោកអ្នកបានចាកចេញនោះទេ ប៉ុន្តែលោកអ្នកអាចធ្វើអញ្ចឹងដោយឆ្លងកាត់ឧបករណ៍មួយចំនួន។ Open Word ដែលមាននៅលើ Windows Phone គឺសម្រាប់ពេលលោកអ្នកចេញទៅខាងក្រៅផ្ទះដែលអាចឲ្យលោកអ្នកអានបន្តបាន។

## ការណែនាំ និងឆ្លើយតបៈ

តើអាចធ្វើសហប្រតិបត្តិការនៅលើឯកសារបានដែរឬទេ? ឥឡូវ Word 2013 ផ្តល់ឲ្យលោកអ្នកនូវលទ្ធភាពនៃការត្រឡប់ someone else's hard work ទៅក្នុងការប្រមូលផ្តុំនៃការពិភាក្សាគ្នា។ ចុចក្នុង Margin របស់ឯកសារបន្ទាប់មកលោកអ្នកបន្ថែមនូវ Comment។ ចុចនៅលើ Comment របស់មនុស្សម្នាក់ផ្សេងទៀតបន្ទាប់មកលោកអ្នកអាច Reply ទៅកាន់វាក្នុងការពិភាក្សាបែបបណ្តាញសារអេឡិចត្រូនិច។



FILE TOOLS VIEW

Our review unit came with black, however there are a range of other colours available and planned including Magenta and Cyan. We've also seen patterned designs as well.

The design of the Lumia 710 is by no means striking, nor is it the worst phone we've ever seen. It is built well, is solid in the hand and comfortable to use.

**Insides**

Strangely from a core spec point of view, like the processor and memory, the Lumia 710 is identical to the Lumia 800. That means you get a 1.4Ghz processor and 512MB of RAM to power your Windows Phone 7 experience. In our tests and having used the Lumia 800 extensively since before the launch in November, this is more than enough to enjoy the operating system and all that you can throw at it.

Whether it is playing games, loading applications, or merely surfing the web (the browser is hardware optimised) there is a plenty of power to go around.

Elsewhere inside you get Bluetooth, Wi-Fi, and GPS connectivity.

So where have the corners been cut? Well for starters you only get 8GB rather than 16GB as found on the Lumia 800, then there is the screen quality LCD over AMOLED and the 5 megapixel camera over 8 megapixels found on the Lumia 800.

**LCD vs AMOLED**

The single biggest most difference you'll spot instantly when looking at the Lumia 710 is that it uses an LCD screen rather than a AMOLED one. That takes away the stunning visual impact you get from the Lumia 800 and presents you with a screen that is rather flat in its colour. The viewing angle isn't as great and in both the white and black themes unless you are looking at it straight on there is a tendency to believe that the screen colours are somewhat under saturated. It certainly isn't as vibrant.

Pocket-lint

## Templates និង Tools:

សម្រាប់ជំនាន់ថ្មីនៃកម្មវិធី Word មានន័យថាវាមាន Template ថ្មីដើម្បីប្រើប្រាស់។ តាមរយៈការបិទកម្មវិធីវានឹងផ្តល់ឲ្យលោកអ្នកនូវ Blog Post, Annual Report, Family Photo Calendar, Sports Certificate, Wedding Invitation និង Host of other pre-set designs ដើម្បីផ្តល់ឲ្យលោកអ្នកនូវការចាប់ផ្តើមពីខាងដើមនៅលើគ្រោងការលោកអ្នក។

## ការកែសម្រួល PDF:

វាមានភាពពិសេសដែលជាតម្រូវការនៅលើប្រព័ន្ធរបស់លោកអ្នកជាពិសេសប្រសិនបើ PDF បិតនៅក្នុងបញ្ហា ហើយបញ្ហានោះគឺជាកញ្ចប់រូបភាព ប៉ុន្តែ Word 2013 នឹងអនុញ្ញាតឲ្យលោកអ្នកបើក និងបង្ហាញឯកសារ PDF ព្រមទាំងអាចកែតម្រូវ (Edit) ពួកវាបានយ៉ាងល្អដែលពិតជាបង្ហាញឲ្យឃើញចំពោះលក្ខណៈខុសចំនុចនៃ PDF ក្នុងទីតាំងដំបូងប៉ុន្តែលោកអ្នកអាចប្រើប្រាស់បានបានធម្មតា។

# Toll Tip

- របៀបប្រើប្រាស់ Compression Files ឬ Folder ក្នុង Windows ដោយមិនប្រើប្រាស់កម្មវិធីបន្ថែម
- របៀបបង្កើតឲ្យកុំព្យូទ័រ Shut Down ដោយស្វ័យប្រវត្តិនៅពេលលោកអ្នកមិនប្រើប្រាស់
- របៀបបង្កើតប៊ូតុង Shutdown / Restart / Lock Icons ក្នុង Windows ដោយខ្លួនឯង
- របៀបបិទ Power Management ក្នុង Windows 7













# របៀបប្រើប្រាស់ Compression Files ឬ Folder ក្នុង Windows ដោយមិនប្រើប្រាស់កម្មវិធីបន្ថែម



ជាការពិតរាល់ពេលលោកអ្នកចង់ Zip Files គឺតែងតែបញ្ចូលកម្មវិធីបន្ថែមដើម្បី Zip Files ទាំងនោះ។ ក៏ប៉ុន្តែនៅក្នុង Windows ដែលលោកអ្នកកំពុងប្រើប្រាស់រាល់ថ្ងៃក៏អាច Zip Files បានដែរ។ NTFS Compression វាអាចធ្វើឲ្យ Files របស់លោកអ្នកមានទំហំតូចនៅលើ Hard Drive។ ម្យ៉ាងទៀតលោកអ្នកអាចដំណើរការ និងប្រើប្រាស់ Fiels តាមធម្មតា ហើយមិនចាំបាច់ធ្វើការ Unzip ទេ។




ដើម្បីចាប់ផ្ដើមដំបូងលោកអ្នកត្រូវចុច Mouse ខាងស្ដាំលើ Files, Folder ឬ Drive ដែលលោកអ្នកចង់ Compress ហើយជ្រើសយកពាក្យ Properties។




បន្ទាប់ចុចលើ Advanced ប៊ូតុង




បន្តទៀតដាក់ធីកលើពាក្យ Compress contents to save disk space រួចចុច OK ប៊ូតុងពីរដង។




ប្រសិនបើលោកអ្នកដាក់ Compression សម្រាប់ Folder នោះ Windows បង្ហាញសារសួរលោកអ្នក: Ask you whether you also want to encrypt subfolders and files ហើយចុច OK ប៉ូងតុង។




សម្រាប់ឧទាហរណ៍នេះយើង Compress លើ Folder មួយជាប្រភេទ Text Files ដែលទំហំដើមរបស់វាគឺ 356 KB ក្រោយពេល Compress គឺ 255 KB វាអាចកាត់បន្ថយទំហំនៃfiles នោះបាន 40% ។




សម្រាប់ Folder ឬ Files ដែលបាន Compress គឺវាប្តូរឈ្មោះរបស់វាមកជាពណ៌ខៀវក្នុង Windows Explorer។




ហើយនៅពេលណាមួយលោកអ្នកចង់ Uncompress មកវិញគ្រាន់តែចូលទៅកាន់ Advanced attributes រួចដោះធីកចេញពីពាក្យ Compress contents to save disk space ជាការស្រេច៕

Question & Answer
QUESTION & ANSWER
ប្រសិនបើមានបញ្ហាសូមទូរស័ព្ទមកកាន់លេខៈ 012 999 140
We live with technology
IT City Magazine

# របៀបបង្កើតឲ្យកុំព្យូទ័រ Shut Down ដោយស្វ័យប្រវត្តិនៅពេល លោកអ្នកមិនប្រើប្រាស់




ដោយឡែកចំពោះការប្រើប្រាស់ជាមួយ Windows រាល់ថ្ងៃលោកអ្នកប្រហែលជាមិនបានដឹងទេថានៅលើ Windows ក៏អាចកំណត់ឲ្យវាដំណើរការ Restart ឬ Shutdown ដោយស្វ័យប្រវត្តិបានដែរ។ ព្រោះថានេះក៏ជាវិធីសាស្រ្តមួយដែលជួយសម្រួលដល់ការប្រើប្រាស់របស់ និងកាត់បន្ថយពេលវេលាលោកអ្នកផងដែរ។ ខាងក្រោយនេះជាការបង្ហាញពីរបៀបកំណត់ឲ្យ Shutdown ដោយស្វ័យប្រត្តិតាមរយៈ Task Scheduler។




លោកអ្នកត្រូវចូលទៅកាន់ Start ប៊ូតុងហើយវាបញ្ចូលពាក្យTask Scheduler ក្នុងប្រអប់ Search។ បន្ទាប់មកផ្ទាំងរបស់ Task Scheduler ឡើង រួចមើលទៅផ្នែកខាងស្តាំជ្រើសយកពាក្យCreate Task។




ឥឡូវតម្រូវឲ្យលោកអ្នកដាក់ឈ្មោះឲ្យ Task ។




ជាបន្តចូលទៅ Triggers Tab ចុចលើ Click New ប៊ូតុង បន្ទាប់កំណត់ Schedule ឲ្យវា។




បន្តទៅ Actions Tab ចុច Click New ប៊ូតុង រួចបញ្ចូលពាក្យ Shutdown ទៅក្នុង Program Box ហើយវាយ /s ទៅក្នុង Parameters box។ ប្រសិនបើលោកអ្នកចង់ឲ្យវា Force Shutdown ហើយបិទនូវកម្មវិធីលោកអ្នកលោកអាចប្រើ /S /F។








បន្ទាប់មកទៀតចុចលើ Conditions Tab ត្រង់ចំនុចនេះលោកអ្នកត្រូវកំណត់សម្រាប់ការបញ្ចប់ Task ក្នុងករណីលោកអ្នកចង់បន្តប្រើប្រាស់កុំព្យូទ័របន្តប្រសិនបើលោកអ្នកមិនចង់ប្រើបន្តវានឹង ដំណើរការដោយស្វ័យប្រវត្តិតាមរយៈពេលដែលបានកំណត់ឲ្យវា។




ចំណែកត្រង់ Settings tab គឺលោកអ្នកអាចកំណត់ឲ្យវា Resart Task រាល់ 30 នាទីម្តង ជៀសវាងនៅពេល Task មិនដំណើរការ។




លោកអ្នកនឹងទទួលបានការ Shutdown ដោយស្វ័យប្រវត្តិតាមរយៈពេលកំណត់៕




# របៀបបង្កើតប៊ូតុង Shutdown / Restart / Lock Icons ក្នុង Windown ដោយខ្លួនឯង




ប្រសិនបើលោកអ្នកមិនចង់ប្រើប្រាស់ជាមួយប៊ូតុង Shutdown / Restart / Lock Icons លើ Windows លោកអ្នកអាចបង្កើតវាបានដោយខ្លួនអ្នកផ្ទាល់ និងប្រើប្រាស់បានយ៉ាងងាយស្រួល និងមិនចំនាយពេលវេលាយូរ។




ជាដំបូងចុច Mouse ខាងស្តាំលើ Desktop ហើយជ្រើសយក ពាក្យ New --> Shortcut។




ជាបន្ទាប់ផ្ទាំងរបស់ Shortcut បង្ហាញឡើង ចំណែកនៅក្នុងប្រអប់ក្រោមពាក្យ Type the Location fo the item ត្រូវបញ្ចូល Command ខាងក្រោមដាក់ក្នុងប្រអប់នោះទៅតាម Shortcut ដែលបង្កើត។




1. Shutdown Computer

   Shutdown.exe -s -t 00

2. Restart Computer

   Shutdown.exe -r -t 00

3. Lock Workstation

   Rundll32.exe User32.dll,LockWorkStation

4. Hibernate Computer

   rundll32.exe PowrProf.dll,SetSuspendState

5. Sleep Computer

   rundll32.exe powrprof.dll,SetSuspendState 0,1,0

ជាបន្តចុច Next រួចដាក់ឈ្មោះឲ្យ Shortcut នោះ។




ហើយចុចប៊ូតុត Finish ក្រោយមកលោកអ្នកទទួលបាន icon ថ្មីមួយ ប្រសិនបើយកចុចពីរដងលើ icon វានឹងដំណើរការទៅតាម Command ដែលបានបញ្ចូលឲ្យ Shortcut។

មួយវិញទៀតប្រសិនបើលោកអ្នកត្រូវការផ្លាស់ប្តូរលើរូប icon នោះគឺត្រូវយក Mouse ដាក់ Select លើ icon នោះរួចយក Properties




បន្ទាប់មកចុចលើ Change Icon ប៊ូតុង ហើយលោកអ្នកនឹងឃើញរូប icon ជាច្រើនដែលមានស្រាប់ក្នុង Windows រួចជ្រើសយក icon មួយណាដែលលោកអ្នកពេញចិត្ត ហើយចុច Ok៕




# របៀបបិទ Power Management ក្នុង Windows 7

នៅពេលលោកអ្នកប្រើប្រាស់កុំព្យូទ័រគឺរាល់ពេលលោក អ្នកឈប់ប្រើប្រាស់វាបន្តិចគឺវាតែងតែ Sleep ដោយស្វ័យប្រវត្តិ ហើយពេលខ្លះលោកអ្នកក៏មានការធុញទ្រាន់ដែរ។ ដូច្នេះដើម្បីស្រាយ បញ្ហានេះសូមមើលការបង្ហាញដូចខាងក្រោម៖

មុនចាប់ផ្តើមតម្រូវឲ្យលោកអ្នកចុចលើ More Power icon




ហើយផ្ទាំងរបស់ Power Options បង្ហាញឡើង ចំណែកនៅក្រោមពាក្យ "Additional plans" ត្រូវ Select លើ High Performance បន្ទាប់ចុចត្រង់ "Change plan settings"។




រីឯចំនុចក្រោមត្រូវផ្លាស់ប្តូរមកពាក្យ "Never" រួចចុច Save ប៊ូតុង។



# New Softwares



## អត្ថប្រយោជន៍ដ៏ច្រើនពី ឯកសារប្រភេទអក្សរទៅជាឯកសារសម្លេង




TextAloud ជាកម្មវិធីដែលមួយមានមុខងារបំប្លែងឯកសារប្រភេទអក្សរដែលភាគច្រើនជាភាសា អង់គ្លេស ទៅកាន់ឯកសារប្រភេទសំឡេងដូចជា (*.mp3) ជាដើម។ ជាមួយនឹងកម្មវិធីនេះផងដែលអាចជួយសម្រួល និងផ្តល់ឲ្យអ្នកប្រើប្រាស់នូវអត្ថប្រយោជន៍ដ៏ច្រើនសន្ធឹកសន្ធាប់ជាពិសេស សិស្សានុសិស្ស ដែលចង់បង្កើតនូវឯកសារសម្លេងជាភាសាអង់គ្លេសនៃអត្ថបទរបស់ខ្លួនឯងផ្ទាល់ទៅជាសម្លេង។ លក្ខណៈប្រើប្រាស់វិញមានភាពងាយស្រួលគ្រាន់តែធ្វើការចុច Click ប៉ុណ្ណោះ៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 18.9 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ដកពិសោធន៍ជាមួយសមត្ថភាពថ្មីលើប្រភេទឯកសារតន្ត្រី



Sound Normalizer គឺជាកម្មវិធីមួយដែលជួយ និងបង្កើននូវកម្រិតសំឡេងរបស់ឯកសារប្រភេទតន្ត្រី ដូចជា Mp3 និង Wav files ជាដើម។ ដំណើរការប្រើប្រាស់ គឺមាននូវមុខងារជាច្រើនសម្រាប់ជាតម្រូវការ ដូចជាមុខងារបង្កើនសំឡេងដោយស្វ័យប្រវត្ត និង មុខងារសាកល្បងនូវចង្វាក់ភ្លេងដែលបានកែប្រែរួច។ មិនត្រឹមតែប៉ុណ្ណោះ Sound Normalizer បានធ្វើការ បន្ថែមនូវ ID3 និង RMS normalization ទៅលើឯកសារតន្ត្រីដែលបានយកមកកែប្រែទាំងនោះទៀតផង៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 6 MB | Mac OS X | www.itcity.com.kh | បានរហូត |

## ប្លែកៗជាមួយ Blu-ray វីដេអូ




ដំណោះស្រាយដ៏ល្អប្រសើរសម្រាប់ការបំប្លែងប្រភេទឯកសារ វីដេអូជាមួយនឹងមុខងារថ្មីរបស់ VSO Blu-ray Converter Ultimate ដែលកម្មវិធីនេះផ្ទាល់ អាចធ្វើការបំប្លែងនូវរាល់ឯកសារ Blu-ray វីដេអូ ឬ AVCHD structure (ជាឯកសារវីដេអូដែលបានមកពីឧបករណ៍សម្រាប់ថតដូចជា Canon, sony, samsung ...)ទៅកាន់ DVD file វីដេអូ ឬទៅកាន់ឯកសារវីដេអូផ្សេងៗជាច្រើនទៀតជាច្រើនដែលសម្រាប់ដាក់ឲ្យដំណើរការ Play លើឧបករណ៍ទំនើបៗនាពេលបច្ចុប្បន្នជាដើមដូចជា PS3, XBOX360, DivX home player, iPod, iPhone, iPad ជាដើម។

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 27.6 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ដំណោះស្រាយដ៏ល្អសម្រាប់ PHP កូដ




phpDesigner ជាកម្មវិធីដែលជួយសម្រួលដល់អ្នកសរសេរកូដ (Programmer) ទៅលើភាសាមួយចំនួនដូចជា PHP IDE , PHP ជាមួយ HTML5, CSS3, javascript ដោយភាពប៉ិនប្រសប់ដំណើរការលឿន ឆ្លាតវៃ និងចំណេញពេលវេលា។ ជាមួយកម្មវិធីនេះដែល គឺបានរួមបញ្ចូលនូវមុខងារថ្មីៗសម្រាប់ជាតម្រូវការអភិវឌ្ឍនូវភាសារកូដរបស់ Developers ។ លើសពីនេះទៅទៀត មិនត្រឹមតែអាចសរសេរបាន ថែមទាំងអាចធ្វើការវិភាគ (analyzing) និង Run កូដ (debugging) ជាមួយគេហទំព័រដែលបង្កើតឡើងពីការសរសេរ PHP, HTML5, CSS3, javascript និង ភាសាកូដដ៏ទៃផ្សេងទៀតទាំងនោះ។ ចាប់ផ្តើមបង្កើតគេហទំព័រ ឬកម្មវិធី web apps របស់លោកអ្នកចាប់ពីឥឡូវជាមួយ phpDesigner ជំនាន់ថ្មី៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 23 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## វិលត្រឡប់មកវិញសារជាថ្មីនូវ Start ប៊ូតុងសម្រាប់ Windows8




ប្រព័ន្ធដំណើរការ Microsoft Windows 8 បានបង្កើតឡើងសម្រាប់តម្រូវការអ្នកប្រើប្រាស់បានទូរទៅនៅគ្រប់មជ្ឈដ្ឋាន និងគ្រប់ទីកន្លែង ប៉ុន្តែអ្វីដែលជាចំណុចគួរឲ្យចាប់អារម្មណ៍នៅលើ Windows 8 នោះគឺមិនមាននូវ Start ប៊ូតុងដូចជា ជំនាន់មុនរបស់ Microsoft Windows ទេដូចជា xp ឬ 7 នោះទេ។ ជួបជាមួយ Startdock Start8 ជំនាន់ 1.1 បានបង្កើតឡើង និងអាចធ្វើឲ្យប្រព័ន្ធដំណើរការ Windows 8 មាននូវ Start ប៊ូតុងឡើងវិញ ដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការប្រើប្រាស់។ ចាប់ផ្តើមថ្ងៃនេះទាំងអស់គ្នាជាមួយនឹង Start ប៊ូតុងនៅលើប្រព័ន្ធដំណើរការ Microsoft Windows 8 របស់លោកអ្នក៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 5 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ជម្រើសដ៏ល្អសម្រាប់ Compress ឯកសារទិន្នន័យ



Winzip គឺជាកម្មវិធីមួយប្រភេទដែលផ្តល់ឲ្យអ្នកប្រើប្រាស់នូវវិធីសាស្ត្រដ៏ល្អបំផុតទៅលើការបង្រួម (Compress) ឬ ពន្លា (Extract) ឯកសារទិន្នន័យផ្សេងៗដូចជា ឯកសារ ចម្រៀង វីដេអូ ឬឯកសារសំខាន់ៗដ៏ទៃផ្សេងទៀត។ ជាមួយជំនាន់ថ្មីរបស់ Winzip 17 នេះបានសិក្សាបង្កើតឡើងផ្តល់នូវភាពងាយក្នុងការស្រួលប្រើប្រាស់ និងមានសុវត្ថភាពខ្ពស់ទៅលើឯកសារ ព្រោះវាបានបន្ថែមនូវប្រព័ន្ធសុវត្ថិភាព AES encryption។ ដោយឡែកកម្មវិធីនេះដែរមិនត្រឹមតែប្រើបានជាមួយប្រភេទឯកសារ (*.zip) ប៉ុណ្ណោះទេ តែផ្ទុយទៅវិញវាអាច Support ជាមួយប្រភេទឯកសារប្រភេទ (Compress) ដ៏ទៃផ្សេងទៀតដូចជា Zip, Zipx, RAR, 7Z, BZ2, LHA, CAB, IMG, ISO និង ឯកសារទាក់ទង់ផ្សេងទៀតជាច្រើន៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 47.3 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ដំណោះស្រាយសម្រាប់ត្រកូល ATI




អស់កង្វល់ទៅលើ Driver VGA (Video Graphics Array) ជាច់ប្រភេទ ATI Catalyst Display នៅលើម៉ាស៊ីនកុំព្យូទ័ររបស់លោកអ្នកទៀតទៅ ជួបជាមួយដំណោះស្រាយដ៏ប្រសើរសម្រាប់លោកអ្នកគឺ កម្មវិធីដែលបង្កើតឡើងដោយក្រុមហ៊ុន ATI មានឈ្មោះថា ATI Catalyst Display Driver ជំនាន់ 13.3 មានសមត្ថភាពបំពេញនូវកង្វះខាត់ Driver VGA ដែលមិនស្គាល់ឲ្យមានសភាពប្រក្រតីឡើងវិញ ។ បន្ថែមពីនេះទៀតនោះ ATI Driver នេះដំណើរការ Support ជាមួយសេរី (VGA ATI Radeon HD) ជំនាន់ថ្មីដូចជា AMD Radeon HD 7900 , HD 7700, HD 7300, HD 6900, HD 6800, HD 6600, HD 6500, HD 6550D, HD 6530D និងមានប្រមាណជាង 50 Series ផ្សេងទៀត។ អាចប្រើបានជាមួយ Driver នេះប្រព័ន្ធដំណើរការ Microsoft Windows Vista/7/8 32bit/64bit៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 94.7 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## ប្រើប្រាស់បានកាន់តែងាយស្រួលទៅលើមុខងារ Upload

CrossFTP ជាកម្មវិធីមួយប្រភេទដែលបង្កើតឡើងក្នុងគោលបំណងផ្តល់ឲ្យអ្នកប្រើប្រាស់នូវមុខងារជាច្រើន ងាយស្រួលទាក់ទងទៅនឹងផ្នែក Uploads ទិន្នន័យផ្សេងៗទៅកាន់ FTP Server ។ ផ្អែកទៅលើមុខងារសំខាន់មួយចំនួនរបស់កម្មវិធីនេះអាចប្រើប្រាស់បានជាមួយការតភ្ជាប់ទៅកាន់ Server FTP ច្រើនបានក្នុងពេលតែមួយ មិនត្រឹមតែអាចប្រើជាមួយនឹងប្រព័ន្ធដំណើរការ Microsoft Windows ប៉ុណ្ណោះទេ ថែមទាំងអាចប្រើប្រាស់បានយ៉ាងទូលំទូលាយជាមួយប្រព័ន្ធដំណើរការដ៏ទៃផ្សេងទៀតដូចជា ពពួក OpenSource (Linux, unix, CentOS...) និងប្រព័ន្ធដំណើរការរបស់ក្រុមហ៊ុន Apple គឺ mac os x ជាដើម៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 4.97 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |



## ជំនួយការពិសេសសម្រាប់ឧបករណ៍ Cisco

Packet Tracer គឺជាកម្មវិធីពិសេសមួយដែលបង្កើតឡើងដោយក្រុមហ៊ុនដ៏ល្បីល្បាញមួយផ្នែក Hardware នៅបណ្តាប្រទេសប៉ែកអឺរ៉ុប គឺក្រុមហ៊ុន Cisco។ និយាយពីសមត្ថភាពចំពោះកម្មវិធីនេះវិញអាចជួយសម្រួលទៅដល់រាល់ការគណនាលើទិន្នន័យ និងការ Config ផ្សេងៗដែលទាក់ទងទៅនឹងផលិតផលទាំងអស់ដែលបង្កើតដោយក្រុមហ៊ុន Cisco ផ្ទាល់។ ទៅលើការប្រើប្រាស់នៃជំនាន់ថ្មីនេះ បានបញ្ចូលបន្ថែមនូវប្រភេទ routers Cisco 7200 និង 7301 series សេរីថ្មី ។ អាចប្រើប្រាស់បានជាមួយនឹងប្រព័ន្ធដំណើរការទាំងអស់របស់ Microsoft តាំងពី Windows XP, VIsta ,7 និងជាពិសេសគឺ Windows 8 នាពេលបច្ចុប្បន្ន៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 185 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |




## ការវិលត្រឡប់មកសាជាថ្មី ចំពោះ StartButton នៅលើ Windows8

8StartButton ជាកម្មវិធីតែមួយដែលអាចមានសមត្ថភាពខ្ពស់ដែលអាចហៅឲ្យត្រឡប់មកវិញនូវមុខងារ Start Menu ដែលគ្មាននៅលើ Microsoft Windows 8 របស់លោកអ្នកឲ្យត្រឡប់មក វិញដោយភាពប៉ិនប្រសប់ និងឆ្លាតវៃ។ លទ្ធផលជាក់ស្តែងដែល 8StartButton អាចធ្វើបានផ្សេងទៀតនោះគឺ អនុញ្ញាតិឲ្យលោកអ្នកប្រើប្រាស់បានច្រើននៅមុខងារទាំងអស់ដូចជាមានសិទ្ធិកែប្រែផ្លាស់ប្តូររូបភាពក៏ដូចជា Command ផ្សេងៗទៅលើប៊ូតុងដូចជា turn off, restart ឬ lock off ទៅម៉ាស៊ីនកុំព្យូទ័រជាដើម៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 15 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |



# QUESTION & ANSWER

ប្រសិនបើមានបញ្ហាសូមទូរស័ព្ទមកកាន់លេខ: 012 999 140
or 6767 ( For Smart Mobile only 3C/mn )

IT City Magazine

## QUESTION & ANSWER

**ឈ្មោះ យុន ផានិត**
panith2012@gmial.com

**សំណួរៈ** ជម្រាបសួរ! ខ្ញុំបាទឈ្មោះ យុន ផានិត ដែលជាប្រិយមិត្តនៃទស្សនាវដ្តីទីក្រុងព័ត៌មានវិទ្យា។ ខ្ញុំមានសំនួរមួយសួរទៅដល់បង សព្វថ្ងៃនេះខ្ញុំមានកុំព្យូទ័រ Laptop ម៉ាក់ Sony ជាមួយនឹងប្រព័ន្ធដំណើរការ license (Windows 7 Home) ប៉ុន្តែដោយពិបាកក្នុងការប្រើ ប្រាស់ពេកខ្ញុំក៏បានយកទៅឲ្យគេតម្លើងប្រព័ន្ធដំណើរថ្មីគឺ Windows 7 Ultimate តែរាល់ពេលដែលខ្ញុំចុចបើកកម្មវិធីយកមកប្រើប្រាស់ម្តងៗវាតែងតែលោតផ្ទាំងមួយគឺឲ្យខ្ញុំចុច Yes ឬ No ។ តើធ្វើយ៉ាងណា ដើម្បីកុំឲ្យលោតផ្ទាំងនេះលោតរំខានទៀតរាល់ពេលបើកកម្មវិធីលើកក្រោយ? សូមបងជួយដោះស្រាយខ្ញុំផងដោយក្តីអនុគ្រោះ។៕




**ចម្លើយៈ** ជម្រាបសួរ នឹងអរគុណចំពោះការគំទ្ររបស់ ផានិត។ សម្រាប់ប្រព័ន្ធដំណើរការថ្មី ដែលប្អូនយកទៅឲ្យគេតម្លើងនោះវាពិតជាមានលក្ខណៈងាយស្រួលប្រើប្រាស់ជាងប្រព័ន្ធចាស់របស់ប្អូនប្រើប្រាស់ពីមុន license (Windows 7 Home) ដែលមានភ្ជាប់មកស្រាប់ជាមួយកុំព្យូទ័រ Laptop Sony នោះ។ ចំពោះប្រព័ន្ធដំណើរ ការថ្មីនេះដែលជា Windows 7 Ultimate វាមាននូវមុខងារប្រើប្រាស់ច្រើនជាងមុន។ ទៅលើការប្រើប្រាស់ដើម្បីមិនចង់ឲ្យមានផ្ទាំងរំខាននោះប្អូនអាចអនុវត្តតាម 3 របៀបផ្សេងៗគ្នាដូចខាងក្រោមៈ

**របៀបទី១:** បិទតាមរយៈ Action Center

ដំបូងចូលទៅកាន់ Start > Control Panel



នៅក្នុងផ្ទាំង Control Panel ចុចលើ User Account



ចុចលើពាក្យ Change User Account Control settings



នៅក្នុងផ្ទាំង User Account Control Settings ប្រើ Mouse ទាញ ដូចរូបខាងក្រោមទៅដល់ចំណុច Never notify រួចបន្តចុចប៊ូតុង OK ជាការស្រេច



**របៀបទី2:** បិទតាមរយៈ Windows Registry

តាមរបៀបទី ២ ប្រើនូវ Keyboard (Start+R) រួចវាយពាក្យ gpedit.msc និងចុចប៊ូតុង OK




នៅក្នុងផ្ទាំង Local Group Policy Editor ចូលទៅកាន់ Computer Configuration > Windows Settings >Security Settings >Local Policies > Security Options រួចនៅផ្នែកខាងស្តាំត្រង់ចំណុច User Account Control ដែលមានពីខាងមុខអាចកែប្រែបានតាមតម្រូវការ។

**ចំណាំ:** នៅរាល់ការកែប្រែរួចត្រូវតែ Restart កុំព្យូទ័រ



**របៀបទី3:** ចូលទៅប្រើប្រាស់ User Account Built-in Administrator

ជាធម្មតានៅពេលដែលម៉ាស៊ីនកុំព្យូទ័រដែលបានដំឡើងថ្មី និងពេលដំណើរការជិតចប់គឺសុទ្ធសឹងតែទាមទារឲ្យវាយបញ្ចូលនូវ User Name ឬក៏លេខសម្ងាត់ (Password) ជានិច្ចៗ ត្រង់ចំណុចនេះហើយនោះគឺមានន័យថា User Name ឬក៏លេខសម្ងាត់ដែលយើងបានដាក់នោះនឹងយកមកប្រើប្រាស់ជាលក្ខណៈទូរទៅតែម្តងដែលមានសិទ្ធ (Member of ) ស្មើនឹង Administrator ដែរតែប៉ុណ្ណោះ ប៉ុន្តែមិនមានជា User Account Buil-in ទេ។ ដូចច្នេះយើងគប្បីប្រើប្រាស់ User Account Buil-in វិញ ទើបរាល់ការប្រើប្រាស់ ឬបើកកម្មវិធីផ្សេងៗមិនមានទាមទារ Yes ឬ No។ ដើម្បីផ្លាស់ប្តូរ Right+Click លើ Computer រួចជ្រើសយកពាក្យ Manage




រួចនៅក្នុងផ្ទាំង Computer Managerment ចូលទៅកាន់ Local User and Group > Users



ផ្នែកខាងស្តាំ Right+Click លើ Administrator Account Buil-in ជ្រើសយក Properties




នៅក្នុងផ្ទាំង Administrator Porperties ត្រូវដោះធីកនៅត្រង់ Account is disabled និងបន្តចុចប៊ូតុង OK




ចំណែកឯ Account ដែលមាន (Member of) Administrator ដែលបង្កើតឡើងពេល Set up windows ថ្មីនោះត្រូវ Right+Click យកពាក្យ Properties ដដែល



រួចនៅក្នុងផ្ទាំង Administrator Porperties ត្រូវធីកត្រង់ ចំណុច Account is disabled ដើម្បីបិទ User Account នេះ ឈប់ប្រើប្រាស់ និងចុចប៊ូតុង OK។ ចុងបញ្ចប់ Restart ម៉ាស៊ីនកុំព្យូទ័រជាការស្រេច៕




Question & Answer
QUESTION & ANSWER
012 999 140
We live with technology
IT City Magazine

# រូបភាពអាថ៌កំបាំង


It's time to have fun!
Tea
HONE
Can you find all the hidden items?


WORM
BIRDS
HOUSE
FLAGS
ENVELOPE
TEPEES
CONE
SOCK
SNOWMAN
BOOT
BALL
SHOE
CUPCAKE
WALNUT
MOUTH
BLACKBERRY

# Word Searc

## SUPERMARKET

| | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| E | Z | U | N | W | Y | Z | G | C | W | I | Q | T | E | I | Z | L | B | C | O | C | F | M | S | S | Z | F | O | A |
| Q | H | E | G | E | X | M | Q | Q | H | M | K | D | P | E | J | K | H | J | E | A | Y | B | Q | J | D | J | V | P |
| S | O | Y | L | C | P | Y | L | P | I | U | Z | I | C | B | N | E | D | A | K | S | G | R | N | I | G | M | Z | G |
| P | U | T | X | X | R | T | C | A | L | B | E | V | E | R | A | G | E | S | R | H | T | M | J | M | W | R | A | H |
| P | S | N | C | R | I | Z | S | E | C | B | F | G | B | J | R | N | K | E | E | I | Q | K | R | K | E | D | W | K |
| R | E | D | C | U | S | T | O | M | E | R | J | F | G | J | M | W | T | P | Y | E | H | T | G | T | O | I | H | S |
| H | H | W | G | N | O | S | W | G | K | N | S | C | R | H | G | S | G | H | Y | R | I | U | N | D | C | A | O | H |
| G | O | L | O | G | W | J | A | M | N | Q | T | S | M | Y | I | Y | Q | Q | C | W | Z | U | P | M | H | I | E | O |
| N | L | W | A | S | Q | K | Y | C | M | L | N | A | I | G | H | H | A | G | S | B | O | C | Y | R | L | R | U | P |
| A | D | X | I | R | E | V | B | Y | V | G | Y | P | E | T | U | L | B | U | Z | C | W | D | L | V | Y | Y | U | P |
| F | I | K | S | X | Z | L | W | E | E | S | T | R | E | B | T | O | E | F | T | S | F | X | B | V | J | P | V | I |
| I | T | S | L | P | M | L | F | N | S | T | H | C | K | Y | X | G | X | U | E | X | E | S | F | P | T | R | Y | N |
| Z | E | N | E | G | W | H | F | X | W | S | Q | O | J | X | W | G | O | R | G | J | G | H | Z | O | W | O | H | G |
| M | M | A | B | R | E | A | D | F | A | M | L | I | P | G | L | K | M | U | Z | P | A | E | I | S | U | D | J | B |
| U | S | C | A | B | T | C | I | C | M | W | X | C | T | P | C | R | O | I | R | V | K | M | D | S | P | U | P | A |
| E | H | K | V | B | A | U | O | K | Z | V | M | K | B | E | I | O | L | E | P | C | Q | O | S | A | B | C | X | S |
| K | H | S | G | A | G | C | O | N | T | M | P | T | H | Z | I | N | T | K | E | H | O | P | S | C | J | T | A | K |
| F | D | I | Q | H | X | D | K | T | V | Y | Y | C | A | I | V | N | G | H | A | G | X | L | D | Y | A | S | B | E |
| R | D | U | N | X | P | Y | K | E | P | E | P | G | H | K | U | J | C | C | D | J | Y | F | M | G | R | L | F | T |
| O | E | B | M | I | L | K | K | V | G | Y | Y | G | R | O | S | B | W | E | A | M | A | R | U | N | S | Q | E | B |
| Z | S | C | K | B | A | G | W | P | D | O | L | O | C | O | I | R | N | I | N | R | F | E | U | N | G | D | L | I |
| E | F | N | E | E | H | V | J | Z | R | P | O | I | R | Y | C | N | M | K | H | Z | T | E | X | N | M | R | L | H |
| N | H | M | K | I | R | W | L | R | V | O | L | D | W | B | A | E | F | U | R | K | G | Z | H | L | Z | Z | D | N |
| F | Q | T | E | B | P | C | E | V | L | E | D | P | S | C | E | Z | R | X | Q | N | W | E | N | X | B | S | G | K |
| O | I | C | G | I | H | T | A | W | D | U | P | U | Y | F | U | L | I | I | S | V | O | R | Q | H | Y | D | N | D |
| O | L | O | R | N | W | Z | V | B | O | D | A | D | C | O | M | K | T | G | E | M | N | J | M | Z | D | B | T | C |
| D | F | P | Y | D | L | V | I | Y | Q | E | B | M | T | E | F | X | G | I | D | S | B | L | H | B | Y | H | M | N |
| S | Q | W | A | P | I | H | Y | N | Z | O | B | M | P | O | E | C | C | J | C | G | Y | G | X | U | Z | F | R | T |
| O | Y | Z | V | R | N | U | P | M | Y | P | Y | N | U | Y | F | A | G | W | H | R | N | V | J | Z | T | K | D | B |

- delicounter
- frozenfoods
- freezer
- diairyproducts
- milk
- self
- scale
- shoppingbasket
- produce
- aisle
- backegoods
- bread
- cannedgoods
- beverages
- householditems
- bin
- customer
- snacks
- shoppingcart
- receipt
- cashregister
- cashier
- conveyorbelt
- groceries
- bag
- checkoutcounter
- check



# អ្នកឯកទេស លើសេវាបញ្ចូលទឹកថ្នាំ Printer
## The Ink Refill Specialist

EPSON Authorized Dealer

**សន្សំសំចៃថវិការបស់លោកអ្នករហូតដល់ 99% ជាមួយផលិតផលរបស់យើងខ្ញុំ !**

**Epson Stylus Photo 1390**
- Affordable High Quality Photo Printing
- Print Size : A3+ / 6 colour dividual ink
- Print Speed: 15 PPM, 5760 dpi printing
- With Refill ink 600ml auto reset chip

**Epson Stylus Photo TX720WD**
- The Photo Enthusiast's All-in-One
- Print Size : A4 / 6 colour dividual ink
- Print Speed: 40 PPM, 5760 dpi printing
- With Refill ink 600ml auto reset chip
- Wireless networking
- Duplex Printing

**Epson Stylus Photo T50/T60**
- The Photo Specialize Printer
- Print Size : A4 / 6 colour dividual ink
- Print Speed: 38 PPM, 5760 dpi printing
- With Refill ink 600ml auto reset chip
- Direct Print CD

**Epson Stylus L350**
- The First Original Ink Tank from EPSON
- Print Size : A4 All in one printer
- Print Speed: 33 PPM, 5760 dpi printing
- With Refill ink l4 bottles 70ml each +2 blacks
- One year warrenty on part and service.

**Epson Stylus L210**
- The First Original Ink Tank from EPSON
- Print Size : A4 All in one printer
- Print Speed: 27 PPM, 5760 dpi printing
- With Refill ink l4 bottles 70ml each
- One year warrenty on part and service.

**Epson Scaner V370/V33**
- Powerful Basic Flatbed Scanner
- 4800x9600 DPI scanning
- 4 customisable buttons
- EpsonScan image enhancement

**Special Promotion**

295 usd

**Epson ME Office 960FWD**
- Compact, Multifunctional, Highly Economical
- Print Size : A4 / 4 colour dividual ink
- Print Speed: 30 PPM, 5760 dpi printing
- Scan Resolution : 1,200 dpi
- With Refill ink 400ml, 4,000 pages A4
- 1.44 inch LCD and Memory Slot



ជំរើសជាច្រើន
These are your choice
ក្រដាស់រូបថត

- មានលក់ និងជួសជុល ម៉ាស៊ីនព្រីនធ័រ ម៉ាក Epson, Canon, HP និងកុំព្យូទ័រគ្រប់ប្រភេទ ។
- មាន ទទួលបញ្ចូលទឹកថ្នាំ និងភ្ជាប់ប្រព័ន្ធទឹកថ្នាំម៉ាស៊ីនព្រីនធ័រ តំលៃថោក ធានាគុណភាពល្អ ។
- ក្រដាស់រូបថត ក្រដាស់នាមប័ណ្ណ និងក្រដាស់ inkjet គ្រប់ប្រភេទ ។
- មានលក់ កម្មវិធីថតរូបវេទមន្ត ព្រីនរូបដាក់លើកែវ និងព្រីនរូបថត ។

**តំលៃថោក គុណភាពល្អ សេវាកម្មទាន់ចិត្ត**

**បោះដុំ និង លក់រាយ ម៉ាស៊ីនព្រីនធ័រ EPSON ទឹកថ្នាំ**

BEST ELECTRONICS

បេស លក់គ្រឿងអេឡិចត្រូនិច
**Best Electronic Solution**
Address: No 594Eo-596Eo, Kompuchea Krom Blvd, Phnom Penh, Cambodia.
Tel : 012 212 904 / 099 762 462 / 097 22 77 997 / 093 555 275 / 023 998 720.
